ឆ្នាំគ្រួសារ
THE YEAR OF FAMILY

# ជីវិត

Life

ចេញផ្សាយលេខ៖ ៥៥

ភូមិភាគភ្នំពេញ ខែឧសភា ឆ្នាំ២០១៩

ព្រឹត្តិបត្រព័ត៌មានពីព្រះសហគមន៍កាតូលិក

# ពិធីរំលឹក មរណបុគ្គល នៅតាំងគោក



*លេខ: ០៨៦/២០១៩-អក*

# សូមគោរពជូន
# លោកឪពុក បងប្រុស បងស្រី និងបងប្អូនទាំងអស់ជាទីស្រឡាញ់!
# ព្រះយេស៊ូមានព្រជន្មរស់ឡើងវិញ! អាលេលូយ៉ា!

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់បេក្ខជនជាច្រើននាក់ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកកាលពីបុណ្យចម្លងកន្លងមកថ្មីៗនេះ ហើយយើងខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះបងប្អូន ១៥៥នាក់ចូលក្នុងគ្រួសារដ៏ធំរបស់ព្រះជាម្ចាស់។

ថ្ងៃនេះយើងបានទទួលដំណឹងដ៏ក្រៀមក្រំអំពីមរណភាពរបស់បងស្រី ហ្គីប៊ែត (Gilberte Masson)។ បងស្រីជាគ្រូអប់រំជំនឿដ៏ពូកែម្នាក់ ដែលបានណែនាំបងប្អូនជាច្រើននាក់ឱ្យក្លាយជាគ្រីស្តបរិស័ទ ហើយបងស្រីក៏បានធ្វើការយ៉ាងយកចិត្តទុកដាក់ជាមួយលោកពុកប៉ុងសូ (Ponchaud) និងលោកគ្រូវង់ ទៅលើសៀវភៅអប់រំជំនឿដែលយើងកំពុងប្រើសព្វថ្ងៃ។ ខ្ញុំជឿជាក់ថា បងស្រីកំពុងអធិដ្ឋានសម្រាប់យើងទាំងអស់គ្នាពីស្ថានបរមសុខមក។

ក្នុងអភិបូជាប្រសិទ្ធិពរប្រេង ខ្ញុំបានប្រកាសអំពីការចាត់តាំងនៅក្នុងភូមិភាគភ្នំពេញរបស់យើងចាប់ពីខែ កក្កដា ២០១៩ គឺចាប់ពី ថ្ងៃទី ១ ខែកក្កដា៖

***១. មណ្ឌលសកម្មភាពភ្នំពេញខាងជើង:***

ក.លោកឪពុក ដាវីឌ ជ័រណាល់ (Fr. David Journault) (Fidei Donum) ជាជំនួយការបូជាចារ្យ

ខ.លោកឪពុក ចន ពេង (Fr. John Peng ) ជាជំនួយការបូជាចារ្យ

***២. មណ្ឌលសកម្មភាពភ្នំពេញថ្មី***

ក.លោកឪពុកវណ្ណាថាយ៉ាន អារ៉ូគីយ៉ាដុស្ស (Fr. Vanathaiyan Arockiadoss) ជាជំនួយការបូជាចារ្យ

ខ.ព្រះសហគមន៍ត្រែងត្រយឹង ដែលពីមុនស្ថិតក្រោមមណ្ឌលសកម្មភាពកំពង់សោម ឥឡូវប្ដូរមកក្រោមមណ្ឌលសកម្មភាពភ្នំពេញថ្មីវិញ។

***៣. មណ្ឌលសកម្មភាពកំពត***

ក.លោកឪពុក កាលេ ណានី ឆារលេស (Fr. Kale Nani Charles) ជាជំនួយការបូជាចារ្យ

***៤. មណ្ឌលសកម្មភាពមេគង្គ***

ក.លោកឪពុក ខូន អាប្រាហាំ (Fr. Khun Abraham) ជាជំនួយការបូជាចារ្យ

ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ លោកឪពុក ហាតាឆៃសាន់ដេ (Fr. Hattachai Wongmasaen Sunday) កំពុងបន្តការសិក្សា។ យើងខ្ញុំសូមជូនពរលោកឪពុកជោគជ័យក្នុងការសិក្សា។

ចាប់ពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ លោកឪពុក ហ្គូស្តាវ៉ូ (Fr. Benitez Gustavo) ដែលកំពុងបម្រើព្រះសហគមន៍នៅមណ្ឌលសកម្មភាពភ្នំពេញខាងជើង នឹងទៅបន្តការសិក្សារយៈពេល ៣ឆ្នាំនៅប្រទេសអ៊ីតាលី។ រយៈពេល ១០ឆ្នាំកន្លងមក លោកឪពុកហ្គូស្តាវ៉ូបានចូលរួមសកម្មភាពជាច្រើនដូចជា សកម្មភាពយុវជនភូមិភាគភ្នំពេញ ក៏ដូចជាយុវជនទូទាំងប្រទេសកម្ពុជា យុវជន FABC, PMS ជាដើម។ យើងខ្ញុំ ទាំងអស់គ្នាសូមថ្លែងអំណរគុណដល់លោកឪពុកហ្គូស្តាវ៉ូ យ៉ាងជ្រាវជ្រៅចំពោះការបម្រើដោយយកចិត្តទុកដាក់ និងសេចក្ដីស្រឡាញ់ ហើយយើងខ្ញុំសូមជូនពរលោកឪពុកជោគជ័យក្នុងការសិក្សា។

*បងប្អូនជាទីស្រឡាញ់!*

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់លោកឪពុកទាំងអស់ដែលជាគង្វាលដ៏សប្បុរស បានខិតខំបម្រើ ស្រឡាញ់ព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញរបស់យើង ដោយជំនឿ និងសេចក្ដីសង្ឃឹម។ សូមបងប្អូនទទួលស្វាគមន៍ និងអធិដ្ឋានសម្រាប់ពួកលោកផង!

*សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូន! អាលេលូយ៉ា!*

ភ្នំពេញ, ថ្ងៃសុក្រ ទី១០ ខែឧសភា ឆ្នាំ២០១៩

+អូលីវីយេ ឆ្មីតអឺស្លែរ

អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ





*N: 086/2019-BP*

# Dear Fathers, Dear Brothers and Sisters, Dear Friends, Jesus is Risen! ALLELUIA

We thanks God for so many baptisms in our Vicariate during the Easter Vigil and warm welcome in the big family of God to our 155 new brothers and sisters.

Today, we just got the sad news of the death of Sister Gilberte Masson. Sister Gilberte was a great catechist to many of our faithful and all the books that we are using for catechesis are her hard work with Father Ponchaud and Lokrou Vong! I am sure that she is praying to all of us from the Heaven.

During the Chrism Mass, I have announced some nominations in our Vicariate for next July 2019:

From 1st July 2019:

**1. Phnom Penh North**

a, Father David Journault (Fidei Donum) is parish assistant.

b, Father John Peng (previously at Kampot) is parish assistant.

**2. Phnom Penh Thmey**

a, Father Vanathaiyan Arockiadoss (previously at Mekong) is Parish assistant

b, The parish of TREYTRAYEOUNG (previously in Sihanoukville sector) is attached to Phnom Penh Thmey Sector.

**3. Kampot**

Father Kale Nani Charles (previously at North Phnom Penh) is parish assistant.

**4. Mekong Sector**

Father Khun Abraham (previously at Sihanoukville) is parish assistant.

Since 1st January 2019, Father Hattachai Wongmasaen John Baptist Sunday (Takeo) is in sabbatical year. We wish him the best in his study.

From 10th June 2019, Father Gustavo Benitez (North Phnom Penh) will leave for 3 years of on-going formation in Italy. During theses last 10 years, Father Gustavo was very active in many areas: Youths for Phnom Penh, Cambodia and FABC, PMS.... We express our gratitude for his service with zeal and love and wish him the best for this time of formation! Thanks Father!

*Dear Brothers and Sisters,*

We thanks so much our dear priests, good shepherd, who try to serve and love our Church in Phnom Penh Vicariate with much faith and hope.

Please welcome them and pray for them!

May God bless all of you! ALLELUIA!

Phnom Penh, 10th May 2019

+Olivier Schmitthaeusler
Apostolic Vicar Phnom Penh



*លោកអភិបាល អេនរីគេ ហ្វីការេដូ កំពុងបង្ហាញអំពីគម្រោងលើកកម្ពស់បរិយាបន្នសង្គមដល់ជនមានពិការភាព។* *រូបភាព ព្រះសហគមន៍បាត់ដំបង*

# ការីតាស់កម្ពុជាបើកដំណើរការគម្រោងលើកកម្ពស់ បរិយាបន្នសង្គមដល់ជនមានពិការភាព

អង្គការការីតាសកម្ពុជា សហការជាមួយអង្គការការីតាស់អាល្លឺម៉ង់បានបើកដំណើរការលើគម្រោងលើកកម្ពស់បរិយាប័ន្នសង្គម ដើម្បីធ្វើការចែករំលែក និងលើកកម្ពស់ដល់ជនរងគ្រោះគ្រប់ស្ថានភាពដែលមាននៅក្នុងសង្គមទាំងផ្លូវចិត្ត និងរាងកាយនាព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ នៅអង្គការការីតាសកម្ពុជាសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយមានតំណាងអង្គការ និងស្ថាប័នពាក់ព័ន្ធមួយចំនួនបានចូលរួមជាច្រើនកុះករ។

លោក គឹម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជាថ្លែងថាគម្រោងថ្មីរបស់អង្គការការីតាសនេះគឺដើម្បីជួយដល់ជនរងគ្រោះមានរយៈពេល ៣ ឆ្នាំ ដោយមានសហប្រតិបត្តិការពីការីតាសអាល្លឺម៉ង់ និងអនុវត្តដោយ ការីតាសកម្ពុជា នៅក្រុងតាខ្មៅ និងសៀមរាប។ លោកបានបន្តថា នេះជាគម្រោងបន្ថែមលើការងារដែលការីតាសកម្ពុជាបានធ្វើក្នុងពេលបច្ចុប្បន្នដែលកំពុងជួយដល់អ្នកក្រីក្រ និងអ្នកដែលគ្មានឱកាសនៅក្នុងសង្គម។

លោកសង្ឃឹមថាគម្រោងនេះនិងពង្រឹងសមត្ថភាពការីតាស់កម្ពុជាដើម្បីលើកកម្ពស់បរិយាប័ន្នដោយមានគោលដៅលើកកម្ពស់សិទ្ធិមនុស្សជាពិសេសសិទ្ធិជនមានពិការភាព។

លោកបានលើកផងដែរថាបន្ទាប់ពីសង្គ្រាម ៤០ ឆ្នាំកម្ពុជាមានការរីកចម្រើនប៉ុន្តែក៏មានឧបសគ្គមួយចំនួនដល់ជនងាយរងគ្រោះជាពិសេសជនមានពិការភាព ដើម្បីចូលរួមក្នុងវិស័យនានាទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ គោលនយោបាយ និងសេដ្ឋកិច្ចជាដើម។ លោកថា ការធ្វើបរិយាប័ន្ននេះធ្វើយ៉ាងណាដើម្បីឱ្យសង្គមរបស់យើងមានការយល់ដឹងមានបរិយាកាសមួយដែលអាចផ្ដល់លទ្ធភាពដោះស្រាយរាល់ឧបសគ្គទាំងអស់ និងស្វាគមន៍ ក៏ដូចជាការផ្ដល់ឱកាស ឱ្យអ្នកងាយរងគ្រោះមានភាពស្មើគ្នា ដើម្បីជួយឱ្យជីវិតរបស់គេកាន់តែប្រសើរឡើង។

លោក អេនរីកេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងជាអភិបាលទទួលខុសត្រូវ នៃអង្គការការីតាស់កម្ពុជា បានមានប្រសាសន៍ថាកម្មវិធីនេះ មានសារៈសំខាន់សម្រាប់ការីតាស់កម្ពុជា ចូលទៅក្នុងសង្គមដើម្បីជួយដល់រដ្ឋាភិបាលកម្ពុជា និងជួយដល់ជនមានពិការភាព។ លោកមានប្រសាសន៍បន្តទៀតថាកម្មវិធីនេះជួយឱ្យគ្រួសារដែលមានជនពិការភាពដែលមិនហ៊ានចូលទៅក្នុងសង្គម។ លោកបញ្ជាក់ថាសព្វថ្ងៃយើងមាន មនុស្សមានជំងឺអូទីសឹមច្រើន ហើយកម្មវិធីនេះអាចជួយឱ្យគាត់ចូលរៀននៅក្នុងសង្គមបាន។

លោកអភិបាលថា ឥឡូវនេះមានកម្មវិធីពិសេសថ្មីគឺជួយឱ្យបងប្អូនដែលមានពិការភាពទូទៅអាចចូលរួមនៅក្នុងសង្គម ដូចមនុស្សទូទៅ។ លោកបន្តទៀតថាឧបសគ្គដែលជនពិការមានគឺមិនមែនមកពីខ្លួនគាត់ផ្ទាល់ទេ គឺជាសង្គមមួយដែលត្រូវមានយុត្តិធម៌សម្រាប់ទាំងអស់គ្នា ដូចជា ពេលដែលជនពិការចូលក្នុងបន្ទប់ទឹកគឺអាចឱ្យរទេះរបស់គាត់ចូលបាន។ លោកអភិបាលគឺគេសង្ឃឹមថាចាប់ពីពេលនេះទៅ យើងមានទស្សនៈថ្មី គឺគិតពីសមត្ថភាពដែលជនពិការមាន ច្រើនជាងបញ្ហាប្រឈមរបស់គេ។ គេមានសមត្ថភាពច្រើនជាងឧបសគ្គដែលគេមាន។

នៅក្រៅពីកិច្ចស្វាគមន៍ និងអនុសាសន៍ផ្សេងៗរបស់ថ្នាក់ដឹកនាំអង្គការការីតាសកម្ពុជា និងអង្គការការីតាស់អាឡឺម៉ង់អ្នកបានចូលរួមទាំងអស់ ក៏បានស្ដាប់អំពីសក្ខីភាពរបស់មាតាបិតា ដែលមានកូនជាជនពិការ និង យុវជនដែលជាជនពិការផ្ទាល់ដែលធ្លាប់ទទួលរងនូវការប្រមាថមើលងាយពីអ្នកជុំវិញ ក៏ប៉ុន្តែ ពួកគាត់នៅតែមានក្ដីសង្ឃឹមថាអាចចូលរួមនៅក្នុងសង្គមដូចគេដូចឯងបាន។

គម្រោង លើកកម្ពស់បរិយាប័ន្នសង្គមនេះនឹងដាក់ឱ្យដំណើរការរយៈពេល ៣ឆ្នាំគឺចាប់ពីឆ្នាំ ២០១៩ រហូតដល់ឆ្នាំ ២០២១។ ក្រៅពីគម្រោងនេះ ការីតាស់កម្ពុជាក៏បានយកចិត្តទុកដាក់ផ្ដល់សេវាកម្មពង្រឹងសមត្ថភាពសម្របសម្រួលលើគ្រប់វិស័យដើម្បីលើកកម្ពស់ជនក្រីក្រដែលមកពីគ្រួសារជនមានពិការភាពជាពិសេស មានការអប់រំជាប្រព័ន្ធសម្រាប់ស្ត្រី និងអប់រំវិជ្ជាជីវៈដល់ស្ត្រីដែលរងគ្រោះដោយសារការបំពានផ្លូវភេទព្រមទាំងយុវជនយុវនារីទាំងអស់ក៏ដូចជាកុមារឱ្យមានបំណិនជីវិតនិងស្វែងរកឱកាសដើម្បីចូលរួមនៅក្នុងសង្គម ក៏ដូចជាការរួមចំណែកនៃការអភិវឌ្ឍសង្គមកម្ពុជាទាំងមូលផងដែរ៕





# CARITAS CAMBODIA LAUNCHES SCHEME TO PROMOTE SOCIAL INCLUSION FOR DISABLED PERSONS

CARITAS Cambodia in collaboration with Caritas Germany launched a scheme to promote social inclusion for people with disabilities in order to share and help mental and physical victims in all forms. The launch of the scheme took place on the morning of 9 April 2019 at its National Office in Prampi Makara district's Boeung Prolit commune in Phnom Penh in the presence of organization's representatives and representatives from relevant institutions.



Executive director of Caritas Cambodia, Kim Rattana said that the new scheme of the organization was to help victims for a period of three years, in collaboration with Caritas Germany. The scheme will be implemented by Caritas Cambodia in Takhmao city and Siem Reap.

There are further schemes on the existing work of Caritas Cambodia currently to help the poor and those who do not have much chance in society. These were highlighted by the executive director.

He hoped that the scheme would strengthen the capacity of Caritas Cambodia to boost inclusion with the objective of promoting human rights, especially rights of people with disabilities.

Forty years after the civil war, Cambodia has made great progress, but there were some obstacles to those who are vulnerable, especially the disabled persons, taking part in various sectors of infrastructure, policies, and the economy and so on, pointed out the executive director.

"The promotion of inclusion is to do what we can in order for our society to have awareness in an atmosphere that enables to address all obstacles and welcome them as well as provide those who are vulnerable with equal chances to help in their livelihoods and improve it well," he said.

Msgr. Enrique Figaredo (also called Kiké) of the Apostolic Prefecture of Battambang and the person in charge of Caritas Cambodia said that the programme was very important for Caritas Cambodia engaging in society to help the Cambodian government and disabled persons. It had helped families whose disabled members do not dare to engage in society. "Today we have a lot of autistic persons and the programme can help them go to school in society," he stressed.

He says now there is a special programme helping disabled person in general who can engage in society like the normal people. Obstacles, which disabled persons faced, are not caused by themselves. It is a society that needs to have justice because when a disabled person enters a bathroom, he or she can steer his wheelchair into it.

Kiké hoped that from now onwards all will have new perspectives in thinking that the disabled persons have more capacities than their challenging problems. They have more capacities than obstacles.

Besides welcome speeches and recommendations made by the leadership of Caritas Cambodia and Caritas Germany, all participants heard testimonial witnesses expressed by parents whose children are disabled persons. They used to meet with disdain from others but they still hope that they could engage in society like everybody else.

This scheme will put into action within a span of three years, from 2019 to 2021. In addition to the scheme, Caritas Cambodia has also improved the services by strengthening their capacities and coordinating all sectors to promote poor ones from families who have disabled persons, knowing that there is the system of education for women and professional education for women suffering from sexual abuses. All youth also have life improving skills and seek an opportunity to engage in society and contribute to the development of Cambodia.

# សួន យឿន៖ «ជំនឿគឺជាសេចក្ដីក្លាហានសម្រាប់ខ្ញុំ»

លោក សួន យឿន វ័យ៧៦ ឆ្នាំ មានកូនប្រុសស្រី៤នាក់ក្នុងក្រុមគ្រួសារជាគ្រីស្ដបរិស័ទ មានទីលំនៅក្នុងសង្កាត់បឹងទំពុន រាជធានីភ្នំពេញ។

ទោះបីជាមានវ័យចាស់បន្ដិចក៏ដោយ តែលោកបានបង្ហាញជំនឿរបស់ខ្លួនថា៖ «ខ្ញុំជឿ និងស្រលាញ់ព្រះជាម្ចាស់តាំងពីដើមរហូតមក បើទោះបីជា មិនទាន់ជាគ្រីស្ដបរ័ទពេញលេញក៏ពិតមែនគឺខ្ញុំតែងផ្ញើជីវិតទាំងស្រុងទៅព្រះជាម្ចាស់ដើម្បីតម្រង់ជីវិត និងបំភ្លឺផ្លូវខ្ញុំកន្លងមកតាមរយៈអធិដ្ឋាន និងការធ្វើទានជាមួយអ្នកដទៃ»។



*លោក សួន យឿន ថ្ងៃទទួលអគ្គសញ្ញាជ្រមុជទឹកនៅបឹងទំពុន។ រូបភាព វណ្ណា*

តាមការឱ្យដឹងពីលោកយឿន គឺលោកបានទទួលរៀនអប់រំជំនឿតាំងពីឆ្នាំ១៩៩២នៅជំរំសាយធូ តែដោយសារតែរវល់ នឹងបំពេញកិច្ចការដើម្បីផ្គត់ផ្គង់ជីវភាព ព្រោះកាលនោះ គ្រួសារលោកជួបការលំបាកជាខ្លាំងរួមនឹងការអាក់អន់ស្រពន់ចិត្តនឹងរឿងរ៉ាវមួយចំនួននាំឱ្យប៉ះទង្គិចផ្លូវចិត្តផង ទើបធ្វើឱ្យលោកមិនបានបន្តការឈ្វេងយល់ជំនឿជាមួយប្រពន្ធកូនរហូតមក។

ក្នុងឆ្នាំ២០១៨លោកបានកែប្រែចិត្តគំនិតពីការជឿលើព្រះយេស៊ូគ្រីស្ដ ដោយមកបន្តរៀនអប់រំជំនឿរហូតបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១៩នៅរាត្រីបុណ្យចម្លង នៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន។

លោកថា៖ «ហេតុនេះខ្ញុំមិនចង់បន្តការឈ្វេងយល់អ្វីទៀត អំពីព្រះយេស៊ូ ដើម្បីបានទទួលឡើយ ព្រោះវ័យក៏ចាស់។ អ្វីដែលសំខាន់គឺខ្ញុំទៅព្រះវិហារ មានទំនាក់ទំនងជាមួយព្រះយេស៊ូរាល់ថ្ងៃទៅបានហើយ។ បើទោះបីជា គ្មានអ្នកណាដឹងតែ ព្រះជាម្ចាស់នឹងយល់អំពីជំនឿខ្ញុំចំពោះទ្រង់»។

លោក យឿន បន្ថែមទៀតថា អ្នកជិតខាង ឬអ្នកធ្លាប់ស្គាល់គ្នា តែងតែនិយាយមិនល្អ ឬសើចយំដោយសេចក្ដីមើលងាយ ដោយសារការចូលសាសនាកាតូលិកនេះ។ តែលោកមិនបានឆ្លើយតបទៅគេវិញទេ គឺលើកលែងទោសឱ្យពួកគេតាមរយៈការថ្វាយទៅព្រះជាម្ចាស់ ត្បិតលោកគិតថាគ្មានអ្នកណា វាស់ជម្រៅចិត្ត និងជំនឿរបស់ខ្លួនបានក្រៅតែពីព្រះជាម្ចាស់ម្នាក់គត់។ ហេតុនេះ ទោះសល់ដង្ហើមចុងក្រោយក៏លោកខំប្រឹងស្វែងរកព្រះអង្គដែរ។

លោក យឿន បន្តថា គាត់ខិតខំទៅព្រះវិហាររាល់ថ្ងៃអាទិត្យ លើកលែងតែពេលគាត់ឈឺប៉ុណ្ណោះ។ ហើយគាត់សប្បាយចិត្តនៅពេលឃើញកូនចៅទៅវិហារ។ បុរសវ័យចំណាស់នេះបន្តថា៖ «មនុស្សចាស់ដូចខ្ញុំមិនដឹងថាមានពេលប៉ុន្មានដងទៀតបានអង្គុយស្ដាប់លោកទេសនា និងជួបជុំគ្រីស្ដបរិស័ទដូចថ្ងៃអាទិត្យ? ហេតុនេះ ការចូលរួមអភិបូជាថ្ងៃអាទិត្យ គឺជាកិច្ចការសំខាន់សំរាប់ខ្ញុំ»។

ក្ដីស្រម៉ៃរបស់លោក សួន យឿន គឺចង់ឱ្យព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាមានការរីកចម្រើនឡើងជាលំដាប់។ មានលោកបូជាចារ្យ និង ដូនជីកាតូលិកខ្មែរជាច្រើន មនុស្សមើលមកគ្នាដោយក្រសែភ្នែកក្ដីស្រលាញ់ និងភាពអាណិតអាសូរគ្នាទៅវិញទៅមក។ ក្នុងព្រះវិហារមានមនុស្សមកថ្វាយអភិបូជាកាន់តែច្រើន ជាពិសេស ឪពុកម្ដាយបញ្ជូនបន្តជំនឿដល់កូនៗពីមួយជំនាន់ទៅមួយជំនាន់មិនឱ្យសាបសូន្យ៕

## The difficult journey of an elderly man in his faith

AN old man Suon Yoeun,76, has four children and resides in Phnom Penh's Boeung Tompun commune.

Though a bit old in age, the 76-year-old expressed his faith, saying: "I have believed and loved God always. Despite not being a full Catholic, I have always offered my entire life to God who directed and enlightened me through prayers and alms-giving to the needy."

According to the old man, he had received education on the essence of the faith since 1992 in the Saythou camp in Thailand, but because he was very busy making a living to survive as his family had met with hardships and somewhat disappointed, thus leading to mental anguish.

He discontinued learning about the faith along with his wife and children from then.

In 2018, he communicated to Jesus in prayer to continue the education of the faith until he got baptised in 2019 at the Easter vigil at the Child Jesus Parish in BoeungTumpon.

He said: "Hence I did not want to continue learning anything about Jesus due to advanced age. What is important is that I go to church, communicate with Jesus every day. That's enough. Although no one knows it, only God knows about my faith in Him."

Yoeun added that neighbours and those whom he used to know, had always spoken ill or mocked in disdain because he had entered this religious belief. He did not respond to them. He had forgiven them by offering them to God for he thinks that no one could measure the depth of a person's heart and his/her faith except the one true God. Hence, he seeks to find Him.

Yoeun continued by saying that he tries to go to church every day, except when he falls sick. He was very happy to see his children go to church. The old man said: "An old man like me, I am unaware of how many times I sat listening to priests delivering their homilies on Sundays? Hence, attending Sunday Mass is a crucial work for me."

Yoeun's dream is that he wanted the Catholic Church in Cambodia to grow from strength to strength with many local Cambodian priests and nuns looking after each other with love in their eyes and with compassion. In church, there are many more people coming to Mass,

Especially parents pass their faith on to their children generation after generation, so as not to lose it.





# បេក្ខជន១២រូបទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូនារាត្រីបុណ្យចម្លង



*បេក្ខជន១២រូបដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកនៅបឹងទំពុន។ រូបភាព វណ្ណា*

ព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន បានប្រារព្ធពិធីអគ្គសញ្ញាជ្រមុជទឹកដល់បេក្ខជន១២រូប ដែលជាសញ្ញាសម្គាល់នៃការទទួលជីវិតថ្មីរួមស្លាប់ និងរួមរស់ជាមួយព្រះគ្រីស្ដ។ ពិធីនេះបានប្រព្រឹត្តទៅនាថ្ងៃទី ២០មេសា ២០១៩ នៅព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្រោមការដឹកនាំដោយលោកបូជាចារ្យ ដាមីញ៉ាំង ហ្វានី និងមានគ្រីស្ដបរិស័ទចម្រុះជាតិសាសន៍ចូលរួមយ៉ាងច្រើនកុះករ។

ក្នុងអង្គពិធីលោកបូជាចារ្យសម្ដែងធម្មទេសនា ដើម្បីដាស់តឿនក្រើនរំឭកដល់គ្រីស្ដបរិស័ទ ជាពិសេសបេក្ខជនទាំងនោះថា៖ ព្រះយេស៊ូបានរស់ឡើងវិញដ៏រុងរឿងពីចំណោមមនុស្សស្លាប់យ៉ាងពិតប្រាកដ និងបន្ដិចទៀតមានមនុស្ស១២នាក់ដែលនឹងជ្រមុជចូលទៅក្នុងទឹកដើម្បីរួមស្លាប់ និងរួមរស់ជាមួយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ លោកបន្តថា ហេតុនេះ គ្រីស្ដបរិស័ទទោះបីជាយ៉ាងណាក៏ដោយចូរមានអំណរសប្បាយ ទោះបីយើងត្រូវគេបៀតបៀន និងទោះបីមានជំងឺក៏ដោយ។ លោកបញ្ជាក់ទៀតថា ជីវិតធម្មជាតិរបស់យើងបានកើតដើម្បីស្លាប់ ប៉ុន្តែជីវិតថ្មីដែលយើងទទួលបានពីអគ្គសញ្ញាជ្រមុជទឹកគឺយើងបានស្លាប់ដើម្បីទទួលជីវិតអស់កល្បជានិច្ច ជាមួយព្រះយេស៊ូដែលបាននាំនូវអ្វីដែលថ្មី ដូច្នេះចូរបងប្អូនក្លាយជាមនុស្សថ្មីក្នុងអង្គព្រះគ្រីស្ដ និងជាពន្លឺដែលចេញពីពន្លឺ។

មុននឹងប្រារព្ធពិធីជ្រមុជទឹក លោកបូជាចារ្យបានសួរបញ្ជាក់អំពីជំនឿរបស់បេក្ខជន និងគ្រីស្ដបរិស័ទ ។ បេក្ខជនទាំង១២រូប បានប្រកាសជំនឿ និងសន្យាព្រមលះបង់ចោលនូវអំពើបាបនានា ដើម្បីរួមដំណើរជាមួយព្រះយេស៊ូ ជាព្រះគ្រីស្ដនិងជាព្រះអម្ចាស់អស់មួយជីវិត។

ទាំងលោកបូជាចារ្យ និងគ្រីស្ដបរិស័ទទាំងអស់បានលុតជង្គង់ ទូលអង្វរព្រះជាម្ចាស់តាមរយៈសន្តបុគ្គលទាំងឡាយ ឱ្យបេក្ខជនដែលហៀបនឹងទទួលអគ្គសញ្ញាជ្រមុជទឹកទាំង១២រូប។ បន្ទាប់មកព្រះសហគមន៍បាននាំបេក្ខជនទៅកាន់អាងទឹក និងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ដើម្បីប្រទានពរលើទឹកដែលជាជីវិត និងបេក្ខជនទាំងអស់ត្រូវបានចុះទៅក្នុងអាងជ្រមុជដោយលោកបូជាចារ្យក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដូចព្រះបណ្ដាំរបស់ព្រះយេស៊ូដែលបានចាត់សាវ័កឱ្យចេញទៅប្រកាសដំណឹងល្អ និងប្រាព្ធពិធីជ្រមុជទឹកដល់អស់អ្នកដែលបានកែប្រែចិត្តគំនិត និងជឿលើដំណឹងល្អ។

ក្រោយមកគ្រីស្ដបរិស័ទថ្មីបានទទួលអាវ៉ស ដែលជានិម្មិតរូបនៃជីវិតថ្មី និងលោកបូជាចារ្យរួមជាមួយបងធម៌នៃជំនឿ បានបំពាក់អាវ៉ស និងប្រគល់ទៀនកំពុងឆេះ ដែលជាព្រះពន្លឺព្រះគ្រីស្ដដល់បេក្ខជន ក៏ដូចជាបំពាក់ព្រះគ្រីស្ដ និងសូមឱ្យពន្លឺព្រះគ្រីស្ដនៅជាមួយបេក្ខជនអស់មួយជីវិតផងដែរ។

ពិធីជ្រមុជទឹកផ្ដល់ឱ្យគ្រីស្ដបរិស័ទមានជីវិតថ្មីក្នុងអង្គព្រះគ្រីស្ដ។ តាមព្រះហឫទ័យរបស់ព្រះអម្ចាស់ យើងត្រូវតែទទួលពិធីជ្រមុជទឹកដើម្បីទទួលការសង្គ្រោះ ដូចជាព្រះសហគមន៍ផ្ទាល់ដែលនាំឱ្យយើងទទួលពិធីជ្រមុជទឹក៕ *(លិខិត១២៧៧)*

## TWELVE CANDIDATES BAPTIZED AT EASTER

THE Child Jesus Parish in BoeungTumpon celebrated Easter with 12 candidates being baptised, which was a sign of renewed life in communion of death and life in Christ. Easter celebration was held on 20 April 2019 in the pastoral sector at the southern zone in Mean Chey district's Boeung-Tumpon commune, Phnom Penh with Fr. Damien Fahrner as the main celebrant. A large number of Catholics attended the celebration.

During his homily, the priest reminded Catholics gathered, especially the 12 candidates, saying that Jesus was truly risen from the dead and after the homily, the 12 were immersed in water in communion with death and life with the Risen Jesus. He continued that hence, Catholics have to be joyful, though we were persecuted.

He stressed: "Our life by nature was birth and death, but renewed life we receive from the sacrament of baptism, we receive renewed life for eternity with Jesus, who led something new. So let brothers and sisters become renewed human beings in Christ and it is a light that springs from the light."

Prior to celebrating baptism, Fr. Damien asked the candidates a few questions about their faith and the Catholic Faith. The 12 professed their faith and promised to abandon sin to make a journey with Jesus – the Christ and Lord for life.

The just baptised candidates received white vestments, which are the symbol of renewed life and purity. The priest and sponsors dressed them in the white garments and handed lit candles to them, which is the light of Christ for the candidates who were dresses like the Risen Christ. "The Light of Christ be with the candidates for life!"

Catechism of the Catholic Church (CCC.1277) says: "Baptism is birth into a new life in Christ. In accordance with the Lord's will, it is necessary for salvation, as is the Church herself, which we enter by Baptism."

# ជនក្រីក្រចំនួន១២០គ្រួសារ ទទួលអំណោយក្នុងឱកាសបុណ្យចូលឆ្នាំថ្មី

គ្រួសារក្រីក្រចំនួន១២០ ទទួលអំណោយពីព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច នាថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៩នេះ ព្រះសហគមន៍សន្តយ៉ូសែបផ្សាតូច ក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង។ កម្មវិធីនេះបានធ្វើឡើងនៅភូមិទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ក្រោមវត្តមានរបស់លោកបូជាចារ្យ ប៉ូល រឿង ឆ័ត្រសិរី ជាប្រធាន រួមជាមួយក្រុមសង្គហៈ និងគ្រីស្តបរិស័ទមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើមលោកបូជាចារ្យ រឿង ឆ័ត្រសិរី ទទួលខុសត្រូវព្រះសហគមន៍ផ្សារតូចផ្ដាល់បានមានមតិស្វាគមន៍បងប្អូនក្រីក្រទាំង១២០គ្រួសារថា៖ ក្នុងឱកាសបុណ្យចម្លង និងបុណ្យចូលឆ្នាំថ្មីប្រពៃណីខាងនេះ ព្រះសហគមន៍យើងបានរៀបចំជាអំណោយបន្តិចបន្តួចដល់បងប្អូន ក្នុងគោលដៅចែករំលែកសេចក្តីស្រឡាញ់ និងចូលរួមរំលែកការលំបាកខ្លះៗដល់បងប្អូន។

លោកបានបន្តថា អំណោយក្នុងថ្ងៃនេះមិនច្រើនទេសម្រាប់គ្រួសារដែលមានសមាជិកច្រើន គឺហូបត្រឹមមួយអាទិត្យ ឬច្រើនជាងមួយអាទិត្យគឺអស់ហើយ តែអ្វីដែលជាគោលដៅនៅក្នុងថ្ងៃនេះ គឺ ព្រះសហគមន៍យើងធ្វើតាមការបង្រៀនរបស់ព្រះយេស៊ូ ឱ្យចេះចែករំលែក ហើយស្រឡាញ់បងប្អូនគ្រប់ជាតិសាសន៍ ដូចឃ្លាមួយបានចែងក្នុងព្រះគម្ពីរថា បើបងប្អូនបានធ្វើកិច្ចការល្អតូចមួយចំពោះនណាម្នាក់ ដូចជាបានធ្វើចំពោះខ្ញុំដែរ។

អ្នកស្រី ស៊ី ផាន ជាប្រធានសង្គហៈរបស់ព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច បានឱ្យដឹងថា អំណោយដែលត្រូវចែកសម្រាប់គ្រួសារនីមួយៗក្នុងថ្ងៃនេះមានដូចជា៖ អង្ករ២៥គីឡូក្រាម ទឹកត្រី មី អំបិល ប្រេងឆា និងត្រីខ។ល។ ហើយគ្រឿងឧបភោគបរិភោគទាំងនេះគឺបានមកពីបងប្អូនគ្រីស្តបរិស័ទ ក្រុងស្រុក និងក្រៅស្រុក រួមជាមួយនឹងថវិការរបស់ព្រះសហគមន៍សន្តយ៉ូសែបផ្ទាល់។



*លោកបូជាចារ្យរឿង ឆ័ត្រសិរី ប្រគល់អំណោយដល់អ្នកក្រីក្រ។* រូបភាព ផ្សារតូច

អ្នកស្រីបានបន្តថា សកម្មភាពចែកអំណោយដល់គ្រួសារក្រីក្រ ក្នុងព្រះសហគមន៍យើងតែងតែធ្វើចំនួន២ដងក្នុងមួយឆ្នាំ។ ហើយបងប្អូនដែលបានចូលរួមក្នុងកម្មវិធីនេះ គឺបានទាំងអំណោយ និងបានលេងកំសាន្តជាមួយល្បែងប្រពៃណីខ្មែរ ឬល្បែងល្បងប្រាជ្ញាយ៉ាងសប្បាយរីករាយទៀតផង៕

# 120 POOR FAMILIES RECEIVE GIFT PARCELS

ONE hundred and twenty poor families received parcels of gifts on 10 April 2019 from St. Joseph's Church in Phsar Toich in the pastoral sector of North of Phnom Penh on the occasion of the Khmer New Year. The event was held in Russey Keo district's Tuol Sangke village, Phnom Penh, in the presence of Fr. Chatsirey Roeung together with members of the Committee for Charity and some other Catholics.



*One hndred and twenty poor families received parcels of gifts.*

Commencing the ceremony, Fr. Chatsirey , the parish priest of Phsar Toich gave the 120 families a very warm welcome, saying: "On the occasion of Easter and Khmer New Year, our parish has prepared little parcels of gifts for you with the aim of sharing love and contributing to alleviate some of your difficulties."

The priest further said: "Today's distribution of the parcels of gifts is not very much for families who large. The parcels of gifts are for one week's supply and then they would run out of the items donated. So what is the aim of today's function, is that our Church follows Jesus' teachings which is to share love and love people of all nations just as the phrase written in the Bible: if you do a good little work for anyone, you do it for me."

Siphan, the chairperson of St. Joseph's parish in Phsar Toich, said that the parcels of gifts which has been distributed for each family member consists of : 25 kg of milled rice, fish sauce, noodles, salt, cooking oil, canned fish, etc. The items had come from local and international Catholics, along with the contribution of St. Joseph's parish itself.

She further said: "The distribution of the parcels of gifts in our Church is done twice a year. The families who had attended the programme either obtained the gifts or earned it by playing traditional Khmer games or even general knowledge quizzes."





# New Bell blessing ceremony at Sacred Heart of Jesus Church

THE Sacred Heart of Jesus Church in Plau Trey of the Mekong River pastoral sector, had a new bell blessing ceremony on the occasion of commemorating the late Fr. François Troeung Buu Yieb on the morning of 12 March 2019 in Love-am Em district's Thmo Ko village in Kandal province. The blessing ceremony was conducted by Bishop Schmittaeusler of the Apostolic Vicariate with thousands of Catholics far and near participating.

The name of the new bell is "Jesus' Sacred Heart". Fr. Werachai Sri Pramong, the parish priest of the Mekong River area, said that the new bell was a new sign of sounding repeatedly to call Catholics to come together to pray in church. The priest also said that the Church before had difficulty at times to gather the faithful because there was no sound to call them. Sometimes, the church's loud-speaker could not be heard at a distance, thereby disrupting gatherings.

The priest added that the bell would be struck three times to make it known to the Catholics: first, to prepare themselves, second prepare to recite a prayer and the third the call for Mass.

At the blessing ceremony, Bishop Olivier invoked God to bless the new bell and the Prelate requested those hearing the sound to gather to glorify Him. This was followed by the Eucharist where he broke bread in memory of Jesus.

The traditional meaning of the bell for the Catholic Church, Fr. Werachai explained: "The bell is the voice of God calling all brothers and sisters to church just as Moses had blown the trumpet to call all people to unite with God."

# ព្រះវិហារព្រះបេះដូងព្រះយេស៊ូ សម្ពោធជួងថ្មី



*លោកអភិបាល អូលីវីយេ កាត់ខ្សែបូសម្ពោធជើងជួងនៅផ្លូវត្រី។* រូបភាព សុវណ្ណភូមិ

ព្រះវិហារព្រះបេះដូងព្រះយេស៊ូ នៅផ្លូវត្រីនៃមណ្ឌលសកម្មភាពទន្លេមេគង្គ បានរៀបចំកម្មវិធីសម្ពោធជួងព្រះវិហារ ក្នុងឱកាសបុណ្យរំឭកដល់លោកបូជាចារ្យហ្វ្រង់ស្វ័រ ត្រឿង ប៊ូយៀប នាព្រឹកថ្ងៃទី១២ មីនា ២០១៩ ក្នុងភូមិថ្មគោ ស្រុកល្វាឯម ខេត្តកណ្តាល ក្រោមអធិបតីភាពលោក អូលីវីយេ ឝ្មិតអឺស្លែរ ដោយមានលោកបូជាចារ្យ និងគ្រីស្តបរិស័ទជិតឆ្ងាយចូលរួមរាប់ពាន់នាក់។

ជួងថ្មីនេះមានឈ្មោះថា «ព្រះបេះដូងព្រះយេស៊ូ»។ លោក ស្រីប្រាម៉ុង វីរៈជ័យ បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពទន្លេមេគង្គ បានមានប្រសាសន៍ថា ជួងនេះជាសញ្ញាមួយដើម្បីបន្លឺឡើងហៅគ្រីស្តបរិស័ទឱ្យមកជួបជុំគ្នាអធិដ្ឋានក្នុងវិហារ។

លោកបូជាចារ្យបានបន្តទៀតថា កាលពីមុនព្រះសហគមន៍នៅទីនេះ មានពេលខ្លះពិបាកក្នុងការជួបជុំគ្នាយអត់មានសំឡេងដើម្បីប្រកាសហៅ និងពេលខ្លះមេក្រូរបស់វិហារមិនឮជាដើមដែលធ្វើឱ្យការជួបជុំត្រូវបានកាត់ផ្តាច់។

លោកបូជាចារ្យបន្ថែមទៀតថា ជួងនេះនឹងវាយចំនួន៣ដងដើម្បីផ្តល់ដំណឹងដល់គ្រីស្តបរិស័ទ។ «ទីមួយ ដើម្បីរៀបចំខ្លួន ទីពីរ រៀបចំសូត្រធម៌ និងទីបីចាប់ផ្តើមថ្វាយអភិបូជា»។

លោកអភិបាល អូលីវីយេ បានទូលអង្វរព្រះជាម្ចាស់ ដើម្បីប្រទានពរដល់ជួងថ្មីនេះ និងសូមឱ្យអស់អ្នកដែលបានឮសំឡេងជួងនេះមកជួបជុំគ្នាដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងប្រារព្ធពិធីកាច់នំប៉័ងដើម្បីនឹករឭកដល់ព្រះយេស៊ូ។

តាមប្រពៃណី និងអត្ថន័យនៃជួងសម្រាប់ព្រះសហគមន៍កាតូលិក លោកបូជាចារ្យ វិរៈជ័យ បញ្ជាក់ថា ជួងជាសំឡេងរបស់ព្រះជាម្ចាស់ដែលហៅបងប្អូនទាំងអស់មកព្រះវិហារ គឺដូចជាលោកម៉ូសេដែលបានផ្លុំត្រែដើម្បីហៅប្រជាជនទាំងអស់ឱ្យមករួបរួមគ្នាជាមួយព្រះជាម្ចាស់ផងដែរ៕





*ពិធីដង្ហែជុំវិញព្រះវិហារថ្មីនៅព្រះសហគមន៍សន្តយ៉ូសែបជុំគិរី ។ រូបភាព សម្បត្តិ*

# ពិធីសម្ពោធព្រះវិហារសន្តយ៉ូសែបជុំគិរី

ព្រះវិហារសន្តយ៉ូសែបជុំគិរីនៃមណ្ឌលសកម្មភាពកំពត ដែលមានប្រវែង ១០ម៉ែត្រ គុណនឹង២០ម៉ែត្រត្រូវបានសម្ពោធឡើងក្រោមអធិបតីភាព លោក អូលីវីយេ ជ្មិតអីស្លែរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ពិធីនេះបានប្រព្រឹត្តឡើងយ៉ាងឱឡារិក នាព្រឹកថ្ងៃទី ១៦ មីនា ២០១៩ នៅស្រុកជុំគិរី ខេត្តកំពត ដោយមានការចូលរួមពីសំណាក់អស់លោកបូជាចារ្យ និងតំណាងគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ចូលរួមយ៉ាងច្រើនកុះករ។

មុននឹងសម្ពោធ លោកអភិបាល លោកបូជាចារ្យ និងតំណាងបរិស័ទទាំងអស់ ដង្ហែជុំវិញព្រះវិហារថ្មីចំនួន បីជុំ តាមក្រោយឈើឆ្កាង អដ្ឋិធាតុរបស់សន្តីតេរេសា ទឹកព្រះពរ និងប្រេងគ្រិស្មា។ បន្ទាប់មកលោកអភិបាលបានសួរ ទៅកាន់លោកថន លូកាដែលទទួលខុសត្រូវនៅព្រះសហគមន៍មណ្ឌលសកម្មភាពកំពតដើម្បីដាក់ឈ្មោះព្រះវិហារថ្មី។ ស្របពេលនេះដែរ លោកតាវ៉ូឡា ថន លូកា ជាគង្វាលនៃព្រះសហគមន៍នេះបានឆ្លើយតបទៅនឹងលោកអភិបាលដោយដាក់ឈ្មោះព្រះវិហារសន្តយ៉ូសែប។

ទន្ទឹមគ្នានេះដែរ លោកអភិបាលអូលីវីយេ បានប្រគល់កូនសោរព្រះវិហារទៅកាន់លោកលូកា ដើម្បីអញ្ជើញគ្រីស្តបរិស័ទទាំងអស់ឱ្យចូលទៅក្នុងព្រះវិហារដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់ ដើម្បីលើកតម្កើងព្រះនាមព្រះអង្គ។

លោកអភិបាលក៏បានដាស់តឿន ដល់លោកបូជាចារ្យ និងគ្រិស្តបរិស័ទនៅទីនេះ សូមឱ្យយកព្រះវិហារដែលជាព្រះដំណាក់របស់ព្រះជាម្ចាស់ទៅជាកន្លែងមួយដើម្បីជួបជុំគ្នាជាក្រុមគ្រួសារ ដោយមានចិត្តស្រឡាញ់ ស្វាគមន៍គ្នា និងលើកលែងទោស លើកទឹកចិត្តគ្នាទៅវិញទៅមក។

បន្ទាប់ពីធម្មទេសនា ទាំងលោកអភិបាល អស់លោកបូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់ លុតជង្គង់រួមគ្នាអធិដ្ឋានអង្វរសន្តបុគ្គលទាំងអស់ ដើម្បីទូលអង្វរព្រះជាម្ចាស់សម្រាប់ព្រះវិហារថ្មីក្លាយជាលំនៅដ្ឋាននៃការសង្គ្រោះ និងធម៌មេត្តាករុណា ដែលគ្រីស្តបរិស័ទទាំងអស់មកថ្វាយបង្គំព្រះជាម្ចាស់ទាំងវិញ្ញាណនិងសេចក្តីពិត។ ក្រោយមកលោកអភិបាលបានបញ្ចុះអដ្ឋិធាតុរបស់សន្តីតេរេសានៅតុសក្ការរួមជាមួយប្រេងគ្រិស្មា ដើម្បីទៅជាសញ្ញាសម្គាល់នៃព្រះរាជ្យ និងព្រះដំណាក់របស់ព្រះគ្រីស្ត និងដុតទៀនបំភ្លឺជុំវិញសសរព្រះវិហារ ជាតំណាងនៃព្រះពន្លឺរបស់ព្រះគ្រីស្ត ដែលបំភ្លឺប្រជាជាតិទាំងឡាយឱ្យបានពោរពេញទៅដោយសេចក្តីពិតផងដែរ។

លោកបូជាចារ្យលូកា បានមានប្រសាសន៍ថា អ្វីដែលធ្វើឱ្យព្រះហគមន៍មានការរីកលូតលាស់មកដល់សព្វថ្ងៃ គឺមកពីការសម្តែងធម៌មេត្តាករុណាតាមរយៈក្រុមសង្គហៈដល់អ្នកជំងឺនៅពេលដែលបងប្អូនកំពុងមានធុរៈ និងមានទុក្ខលំបាក ព្រះសហគមន៍តែងតែព្យាយាមជួយ។ លោកបន្តថា មួយវិញទៀតយើងមានកម្មវិធីផ្សេងៗ ដូចជាកម្មវិធីយុវជនដែលចុះទៅសួរសុខទុក្ខ និងមានកម្មវិធីសប្បាយរួមគ្នាដើម្បីលើកទឹកចិត្តដល់ក្រុមគ្រួសារ ក៏ដូចជាមានអាហារសាមគ្គី និងដូចជាក្រុមស្រ្តីដែលមានការច្នៃប្រឌិតផលិតផលសិប្បកម្មនានា ដែលនាំឱ្យយើងមានអារម្មណ៍ថាជាគ្រួសារតែមួយពិតមែន។

ព្រះសហគមន៍ជុំគិរី បានចាប់ផ្តើមមានឡើងតាមរយៈគ្រួសារគ្រីស្តបរិស័ទមួយដែលបានធ្វើមាតុភូមិនិវត្តពីទល់ដែនខ្មែរ-ថៃ នាឆ្នាំ១៩៩៣ ដោយមានការជួយជ្រោមជ្រែង និងលើកទឹកចិត្តពីលោកអភិបាល អ៊ីវ៉ាម៉ូស លោកបូជាចារ្យវីរៈជ័យ លោកបូជាចារ្យសួន ហង្សលី និងលោកបូជាចារ្យអូលីវីយេ មុននឹងតែងតាំងជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ៕

## St. Joseph's Church Inaugurated

ST. JOSEPH'S CHURCH (Chumkiri) in the Kampot pastoral sector, was inaugurated with the blessing by bishop Olivier Schmitthaeusler of the Apostolic Vicariate of Phnom Penh as the main celebrant. The solemn function took place on the morning of 16 March 2019 in Kampotprovince's Chumkiri district with a large number of people including priests, Phnom Penh diocesan representatives and parishioners in attendance.

Commencing the function, all members of the congregation along with priests walked in procession three times around the new church behind the Cross, while praying and carrying the relics of St. Therese, Holy Water and the Chrism. Later, bishop Olivier asked Fr. GianlucaTavola who is the parish priest of the Kampot pastoral sector to name the new church measuring 10m by 20m.

The priest answered the bishop by saying, "St. Joseph's church".

In the meantime, the bishop handed the key of the church to Fr. Gianluca who invited toall Catholics gathered to enter the church, which is the House of God by praising His name.

Bishop Olivier also advised the priests and parishioners to remember that the church is the House of God and a place for congregating as a family with love, forgiveness and encouragement for one another.

Following the homily, the bishop, all the priests and Catholics went down on their knees and prayed the Litany of the Saints to petition God for the new church to become a dwelling of salvation and compassion when all Catholics come to worship God in the spirit andtruth. The bishop then embedded the sacred relics of St. Therese in the table of the altar and anointed it with Chrism to become the hallmark of the Kingdom and the House of God and candles were lit around the church, which embodies the Light of Christ enlightening all nations to be also filled with the truth.

Fr. Gianluca said that what has made the church grow to date is attributed to charity in action through the Charity group for the sick when they had difficulties and the Church had always strived to lend a helping hand. The priest continued: "In other words, we have a variety of activities such as the visiting of youth and amusement programmes together to encourage families, have fellowship meals and handicraft-processing groups leading us to show that we are truly one family."

Chumkiri Church commenced with one family who were repatriated from the Cambodian-Thailand border in 1993 with the support of and encouragement by former bishop Yves Rammouse and Frs. Werachai Pramong and Suon Hangly and the then-Fr. Olivier Schmitthaeusler.





# បងប្អូន៥៥នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក នៅព្រះវិហារសន្តញញឹម ចំការទៀង

បងប្អូនចំនួន ៥៥ នាក់ ដែលមកពីបួនកន្លែងផ្សេងៗគ្នាក្នុងខេត្តតាកែវ បានទទួលអគ្គសញ្ញាជ្រមុជទឹក នៅព្រះវិហារសន្តីម៉ារីញញឹម ចំការទៀង នៅក្នុងរាត្រីបុណ្យចម្លង កាលពីថ្ងៃអាទិត្យ ទី២១ ខែមេសា ឆ្នាំ២០១៩ កន្លងទៅ ក្រោមអធិបតិភាពរបស់លោកអភិបាលអូលីវីយេ។

បងប្អូនទាំងនោះបានធ្វើដំណើរមកពីព្រះសហគមន៍ត្រពាំងក្រញូង ជាព្រះសហគមន៍ថ្មី ដែលមានអ្នកទទួលអគ្គសញ្ញាជ្រមុទឹកលើកដំបូង។ បងប្អូនមកពីព្រះសហគមន៍សន្តប៉ូល បងប្អូនមកពី ព្រះសហគមន៍តាកែវក្រុង និងបងប្អូនមកពីព្រះសហគមន៍សន្តីម៉ារីញញឹមផ្ទាល់។

ព្រះសហគមន៍កាតូលិកក្នុងខេត្តតាកែវ បានកើតឡើងក្នុងពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ ដោយគ្រីស្តបរិស័ទតែម្នាក់ដែលបានខិតខំឈ្វេងយល់ព្រះបន្ទូល នៅភ្នំពេញ រហូតទទួលអគ្គសញ្ញាជ្រមុជទឹក។ ដោយការខិតខំបង្ហាញជំនឿ និងមានការជួយជ្រោមជ្រែង ពីសំណាក់លោកបូជាចារ្យអូលីវីយេ។ បន្តិចម្តងៗ ដំណឹងល្អអំពីព្រះយេស៊ូបានរីកសាយភាយក្នុងខេត្តនេះ មនុស្សជាច្រើនបានដើរតាមព្រះយេស៊ូ។ ពេលនេះក្នុងខេត្តតាកែវមានព្រះសហគមន៍កាតូលិកចំនួន ៧កន្លែង។

ក្នុងឱកាសបុណ្យចម្លងនេះ ក្រៅពីបងប្អូនចំនួន ៥៥នាក់ដែលជ្រមុជទឹកនៅព្រះសហគមន៍សន្តីម៉ារីញញឹម ក៏មានបងប្អូន ១៨ នាក់ ទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រៃកប្បាស និង ៥ នាក់ នៅព្រះសហគមន៍កាតូលិកគីរីវង់ ក្នុងខេត្តតាកែវផងដែរ។

ចំណែកយុវជន ឌុន ដាវីត ដែលទើបទទួលអគ្គសញ្ញាជ្រមុជទឹកដែរនោះ បានឱ្យដឹងថា៖ «នៅពេលដែលខ្ញុំបានជ្រមុជទឹករួចខ្ញុំមានអារម្មណ៍រំភើបណាស់ ហើយខ្ញុំសប្បាយចិត្តជាខ្លាំង ដោយសារតែខ្ញុំរង់ចាំពេលនេះយូរមកហើយ»។ ដាវីត បន្តថា៖ «ជាពេលវេលាដែលខ្ញុំគិតថាសំខាន់បំផុតសំរាប់ខ្ញុំគឺជាពេលវេលាធ្វើឱ្យមានជីវិតថ្មីកើតម្តងទៀត»។

ក្នុងធម្មទេសនាសម្រាប់រាត្រីបុណ្យចម្លង លោកអភិបាលអូលីវីយេបាន រំលឹកដល់គ្រីស្តបរិស័ទទាំងនៅក្នុងខេត្តតាកែវ ក៏ដូចជានៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញទាំងមូល ចាកចេញពីភាពអាត្មានិយម គិតតែគ្រួសារផ្ទាល់ខ្លួន សុខមាលភាពផ្ទាល់ខ្លួន ឱ្យយកចិត្តទុកដាក់បើកភ្នែកបើកដួងចិត្តចំហរយ៉ាងធំណាស់ ដើម្បីស្រលាញ់ ចំពោះបងប្អូនក្រីក្រ កុមារកំព្រា ស្ត្រីមេម៉ាយ និងចាស់ជរា។



*បេក្ខជន៥៥នាក់ដែលទទួលអគ្គសញ្ញាជ្រមុជទឹកនៅចំការទៀង។ រូបភាព ហំ*

លោកបានបន្តទៀតថា៖ «យើងជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម និងជាគ្រួសារមួយយ៉ាងធំ ដែលមានសមត្ថភាពបង្កើតភាតរភាពនៅក្នុងពិភពលោក។ ដូច្នេះមនុស្សដែលចង់សម្លាប់មនុស្ស មនុស្សដែលចង់សម្លាប់អ្នកដទៃ មនុស្សដែលចង់ធ្វើបាបអ្នកដទៃ មិនអាចឈ្នះទេ ដោយសារមានតែភាតរភាព។ យើងជាមនុស្សដែលចេះលើកទឹកចិត្តគ្នា។ យើងជាគ្រួសារមួយយ៉ាងធំដែលចេះស្រលាញ់គ្នា ជាមួយនឹងសេចក្តីស្រលាញ់របស់យើង»។

លោកបន្តថា៖ «គិតទៅ! នៅក្នុងខេត្តតាកែវ នៅក្នុងប្រទេសកម្ពុជា នៅក្នុងពិភពលោកទាំងមូល ប្រសិនបើគ្រីស្តបរិស័ទទាំងអស់ និងមនុស្សទាំងអស់ ដែលមានចិត្តល្អ ដែលមានចិត្តសុចរិត អាចចាប់ដៃគ្នា ដើម្បីធ្វើដំណើរជាមួយគ្នា មនុស្សដែលមានចិត្តឃោរឃៅ មនុស្សដែលមានចិត្តអាក្រក់មិនអាចឈ្នះទេ។ មានតែសេចក្តីស្រលាញ់ មានតែភាតរភាពដែលជោគជ័យ នេះជាអត្ថន័យ នៃព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ»។

ក្នុងឱកាសនេះដែរ លោកអភិបាលក៏បានលើកទឹកចិត្តឱ្យ គ្រីស្តបរិស័ទទាំងអស់ថែរក្សាជីវិតខាងវិញ្ញាណ ដោយភ្ជាប់ទំនាក់ទំនងជាមួយព្រះជាម្ចាស់។ លោកអភិបាលបញ្ជាក់ថា៖ «នៅយប់នេះ ជាយប់ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាយប់ដែលព្រះបិតាបង្ហាញសេចក្តីស្រលាញ់របស់ព្រះអង្គ ដែលណែនាំឱ្យព្រះយេស៊ូ ចេញពីភាពងងឹតនៃសេចក្តីស្លាប់ ដើម្បីចូលនៅក្នុងពន្លឺនៃជីវិត។

ក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងមូលមានបងប្អូនទទួលអគ្គសញ្ញាជ្រមុជទឹកក្នុង

## 55 CANDIDATES GET BAPTISM

OUR Lady of the Smile Parish in Chamkar Teang celebrated Easter with 55 candidates from four places being baptised. The celebration of Easter was officiated by bishop Oliver Schmitthaeusler of the Apostolic Vicariate of Phnom Penh on 21 April 2019 in Takeo province.

The 55 candidates who had come from these Churches were, Trapang Krongoung – a new Church, St. Paul's Church, Takeo city and Our Lady of the Smiles Parish.

The provincial parish was established in the mid-1990s with only one Catholic who had tried to learn about the Word of God in Phnom Penh until he received baptism. By trying to express the faith and the support from the then-Fr. Olivier, gradually the Gospel of Jesus had spread in the province by many people following Jesus. Now in the province, there are seven parishes.

Another youth Don Davit said: "When I got baptised, I feel very excited and happy because I have waited for this a long time ago.

It is the time when I think that it is most important for me –it is the time to have life re-born."

The youth further said that since he had known the Church, Jesus, there were several changes in his life – the focus is on brothers and sisters helping more than he had not yet known Jesus, especially opening his heart wide to all brothers and sisters. He had vowed to continue taking God as a model of renewed life forever.

During his homily at Easter night vigil, Bishop Olivier further elaborated: "Brothers and sisters, tonight Jesus has risen. Alleluia! Alleluia! The bishop also reminded all parishioners in the province and the whole Phnom Penh diocese alike, to detach themselves from selfishness, thinking of one's own self-interest, own well-being and to turn to attentively opening one's eyes and hearts very wide to love the destitute, orphans, widows and the elderly.

He has also urged Catholics to build fraternity among themselves because all are brothers and sisters in Jesus. He added: "We are the people of hope and a large family who have the capacity to create fraternity in the world. On this occasion, the bishop encouraged all the parishioners to take care of spiritual life by connecting with God. He also commented: "Tonight is a night that Jesus is Risen – a night that the Father shows His love, which leads Jesus out of the darkness of death to go into the light of life".

The whole Catholic Diocese of Phnom Penh had 150 candidates receiving baptism during Easter celebrations in 2019.

# ពិធីរំលឹកមរណបុគ្គលនៅតាំងគោក

កាលពីថ្ងៃទី២០ ខែឧសភា កន្លងទៅនេះ ព្រះសហគមន៍កាតូលិកកម្ពុជាបានប្រារព្ធកម្មវិធីរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មក្នុងរបបប្រល័យពូជសាសន៍ប៉ុល ពត នៅព្រះសហគមន៍តាំងគោក ក្នុងខេត្តកំពង់ធំ ដោយមានលោកអភិបាលអូលីវីយេ ជ្មីតអីស្លឺរ៍, លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ, លោកអភិបាលអេនរីគេ ហ្វីការេដូ រួមនឹងបូជាចារ្យ អ្នកបួស និងគ្រីស្តបរិស័ទជាង២០០០នាក់ចូលរួម។

នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេមានប្រសាសន៍ថា យើងត្រូវរួមជាមួយគ្នា ដើម្បីទទួលខុសត្រូវនៅលើព្រះសហគមន៍កម្ពុជា ដែលយើងទទួលជាមរតក ដើម្បីរៀបចំអនាគតនៃអនាគត។ លោកអភិបាលបញ្ជាក់ទៀតថា ការទទួលខុសត្រូវនោះត្រូវបម្រើដូចព្រះយេស៊ូនៅក្នុងព្រះសហគមន៍ដែលជាផ្ទះផ្ទាល់របស់យើងនៅក្នុងមហាគ្រួសារ ដោយឱ្យអ្នកដទៃរកឃើញសេចក្តីសុខទទួលស្វាគមន៍ ដោយញញឹម និងស្រលាញ់ ជាពិសេសគឺផ្តល់ក្តីសង្ឃឹម។

លោកអភិបាលបានប្រសាសន៍ទៅកាន់ក្រុមអ្នកបួសថា៖ «ដូច្នេះសម្រាប់យើងនៅថ្ងៃនេះ យើងត្រូវនឹកឃើញការទទួលខុសត្រូវរបស់យើង។ ជាពេលដែលយើងនឹកឃើញ ឱ្យងាប់នូវទម្លាប់អាក្រក់ បណ្តេញអ្វីៗដែលនាំយើងឱ្យទៅឆ្ងាយពីព្រះជាម្ចាស់។ ជាពិសេសជាពេលដែលធ្វើឱ្យងាប់នូវវប្បធម៌របស់យើងផ្ទាល់ អំពីទស្សនៈ អំពីពិភពលោកដែលយើងមាន ដើម្បីបញ្ចូលនៅក្នុងទឹកដី និងដើម្បីកើតសារជាថ្មី ដោយមានភ្នែកថ្មី ដួងចិត្តថ្មី»។



*លោកបូជាចារ្យគោរពអាសនៈក្នុងកម្មវិធីគោរពមរណបុគ្គលនៅតាំងគោក។ រូបភាព សុវណ្ណភូមិ*

លោកអភិបាលបញ្ជាក់ទៀតថា៖ «ឱ្យយើងមើលឃើញវប្បធម៌របស់យើងជាវប្បធម៌ខ្មែរ ដោយកើតសារជាថ្មីជាមួយប្រជារាស្ត្រដែលអង្គុយនៅទីនេះ ដែលទៅជាប្រជារាស្ត្ររបស់យើងផ្ទាល់»។

លោកអភិបាលក៏បានជំរុញ និងលើកទឹកចិត្តដល់យុវជន និងគ្រីស្តបរិស័ទទាំងអស់ឱ្យបំពេញនូវគម្រោងការ និងក្តីសុបិនរបស់ខ្លួន និងត្រូវចូលរួមប្រកាសដំណឹងល្អ។

លោកបន្ថែមថា ថ្ងៃនេះ យើងបន្តស្តាប់សំឡេងរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ដែលបានបូជាជីវិតនៅក្នុងអំឡុងរបបប៉ុលពត ដែលជាគំរូនៃជំនឿ ស្តែងចេញដោយសារបម្រើ អធិដ្ឋាននៅក្នុងភាពស្ងៀមស្ងាត់និងលាក់កំបាំង។

នៅក្នុងរបបប្រល័យពូជសាសន៍ប៉ុល ពត អ្វីៗគ្រប់យ៉ាងត្រូវបានបំផ្លាញ រួមទាំងសាសនាផងដែរ ដែលមនុស្សជាច្រើនបានហៅថា «ឆ្នាំសូន្យ»។ ប្រជាជនគ្មានសេរីភាព គ្មានការអប់រំ គ្មានការប្រតិបត្តិសាសនា គ្មានគ្រួសារគឺអ្វីៗត្រូវស្ថិតក្រោមការគ្រប់គ្រងដោយអង្គការ។ ប្រជាជនត្រូវធ្វើការងារយ៉ាងទម្ងន់នៅលើវាលស្រែដោយខ្វះខាតអាហារ។

លោកអភិបាលខ្មែរ យ៉ូសែប ឆ្មារសាឡាស់ និងសហការីរបស់គាត់, លោកអភិបាលទេពអ៊ឹម សុត្ថា រួមនិងបូជាចារ្យ និងបងប្រុស បងស្រី ត្រូវបានស្លាប់ និងសម្លាប់នៅក្នុងរបបវាលពិឃាតមួយនេះ។ តាមការឱ្យដឹងរបស់រដ្ឋាភិបាល ក្នុងរបបនេះ មានអ្នកស្លាប់ចំនួនប្រមាណជិត២លាននាក់។

ជាមួយគ្នានេះដែរ លោកអភិបាលអូលីវីយេបានសុំឱ្យគ្រីស្តបរិស័ទចេះស្វែងរកអ្នកក្រីក្រដែលស្រេកឃ្លាន ដែលមិនត្រឹមតែរូបកាយប៉ុណ្ណោះទេ តែជាវិញ្ញាណ ដែលរួមជាមួយព្រះជាម្ចាស់។



*លោកអភិបាល អូលីវីយេ។ រូបភាព សម្បត្តិ*

មុនពេលបិទបញ្ចប់ធម្មទេសនា លោកអភិបាលបានចោទសំណួរបី ដើម្បីឱ្យគ្រីស្តបរិស័ទឆ្លើយតប។ លោកអភិបាលអូលីវីយេ «គ្រីស្តបរិស័ទត្រូវសុខចិត្តទទួលខុសត្រូវព្រះសហគមន៍របស់ខ្លួន អស់ពីជំនឿ និងសេចក្តីក្លាហាន, សុខចិត្តប្រកាសដំណឹងល្អ ដោយលះបង់ចោលមាសាតាំង និងអ្វីដែលរារាំងផ្លូវក្នុងការប្រកាសដំណឹងល្អ, សុខចិត្តបើកដួងចិត្តយ៉ាងពិតប្រាកដ ដើម្បីមានចិត្តស្រឡាញ់ អាណិតមេត្តាដល់មនុស្សតូចតាចនៅក្នុងសង្គម»។

បងស្រី ស្រី សុជាតិ ជាដូនជីក្នុងក្រុមគ្រួសារស្រលាញ់ឈើឆ្កាងព្រះយេស៊ូមានប្រសាសន៍ថា វាជារឿងសំខាន់ណាស់ដែលយើងប្រារព្ធពិធីរំលឹកអំពីអ្នកស្លាប់ដោយជំនឿនៅថ្ងៃនេះ។

បងស្រី សុជាតិ៖ «ពួកគាត់គឺជាគំរូ និងជាគ្រឹះនៃជំនឿរបស់យើង ដែលនាំឱ្យយើងទាំងអស់គ្នាមានគ្រឹះរឹងមាំបន្តជំនឿនេះនៅក្នុងព្រះសហគមន៍រហូតមកដល់សព្វថ្ងៃ»។

លោកអ៊ឹង ទ្រីអាយុ៧៦ឆ្នាំជាគ្រីស្តបរិស័ទបានឱ្យដឹងថា គាត់មិនដែលបំភ្លេចបទពិសោធក្នុងរបបប៉ុល ពតនោះទេ។ លោកបន្តថា លោកត្រូវបានបង្ខំឱ្យធ្វើការងារលើកទំនប់ដោយគ្មានអាហារគ្រប់គ្រាន់។ លោកថា «៣កំប៉ុង មនុស្សមួយកងចល័ត ៤០នាក់»។

ក្នុងរបបនេះ លោកទ្រីបានបាត់បង់ញាតិសន្តានប្រមាណជា១៥នាក់។ គាត់និយាយថា ដោយសារជំនឿចំពោះព្រះជាម្ចាស់ គាត់បានអត់ទោសឱ្យពួកគេដែលបានធ្វើបាបរូបលោក និងសាច់ញាតិ។ លោកអ៊ឹងទ្រី បាននិយាយថា៖ «ដោយសារយើងជឿលើព្រះបន្ទូល យើងមានមេត្តាករុណា។ យើងអត់មានចងកំហឹងលើគាត់ទៀតទេ។ (អធិដ្ឋាន) ទៅព្រះជាម្ចាស់ទទួលគាត់ផងដែរ»៕





# COMMEMORATING LIVES OF MARTYRS

BISHOP Olivier Schmitthaeusler, the two Apostolic Prefects, Enrique Figaredo ( also known as Kiké) of Battambang and Antonysamy Susairaj of Kampong Cham, priests, religious plus over 2,000 parishioners of the Catholic Church in Cambodia gathered on 20 May 2019 at the annual event in Kampong Thom province's Taingkok shrine to commemorate the dead and suffering Catholics in the 1975-1979 Pol Pot regime.



During his homily, bishop Olivier said: "We must to be united in responsibility for the Church in Cambodia we have inherited from the previous martyrs in preparation for a future. Responsibility is to serve the Church as Jesus, who is our own House in a large family by letting other people discover happiness in receiving welcome with smiles and love, especially providing them with hope."

The bishop further said: "So for us today, we must remember our responsibility. It is a time we remember it to kill bad habits to ward off what leads us away from God. It is a time when it kills our own cultures of viewpoints, the world in which we have to incorporate it into land and to be reborn with new eyes, hearts."

The bishop also commented: "Let us see our cultures as Khmer being reborn along with the Cambodians who sit here, to be become our own people."

The bishop has urged and encouraged all youths and Catholics to fulfil their schemes and realise their dreams and take part in spreading the Gospel.

He added: "Today we proceed to listen to the voice of the servants of God who had offered their lives during the Pol Pot regime, who are the model of the faith due to services, prayer in silence and mystery."

During the Pol Pot regime, everything had been destroyed and demolished, including religion. A number of people called it "Zero Year". The people had no freedom, education. They were even not allowed to practise their religion, had no families – everything under the oppression of Angkar (the all-seeing and all-controlling organization). The people had been subject to hard labour in the rice paddy, facing starvation.

Joseph Chhmar Salas, the local Khmer bishop of Phnom Penh and his companions, bishop Paul Tep Im Sotha, brothers and nuns died and were killed in the Killing Fields, where the Khmer Rouge regime executed nearly two million people between 1975 and 1979.

Bishop Olivier has requested the Catholics to find the hungry not only in a physical manner but also a spiritual one in communion with God.

Before concluding his homily, the bishop asked the worshippers three questions. He continued: "The Catholics must be willing to take responsibility for their Church with all the faith and courage. Be willing to spread Gospel values by abandoning the devil and what stands in the way of preaching the Gospel. Be willing to really open one's heart wide to having love, pity for the unfortunate in society."

Sr. Srey Socheat belonging to the congregation of the Sisters Lovers of the Cross of Jesus, said: "It is very important that we observe the memorial day to pay homage to those killed in the civil war, who gave their life witnessing their faith today.

The nun further said: "They are the model and the foundations of our faith, which leads all of us to have the strong foundations in the Church until now."

Ung Try, 76, a Catholic added that he had never forgotten a very painful experience in the regime. He had been forced to work to raise the dam with no sufficient food – "three cans of milled rice for mobile forces of 40".

During the regime, he had lost fifteen of his relatives. He further elaborated that by the faith in God, he had forgiven them who had mistreated him and his relatives. Try continued: "For we believe in the Word of God, we have compassion. We do not even hold grudge against them, we pray to God receiving them."



*ការបង្ហាតកុមារពិការភាពនៅក្នុងមណ្ឌលភូមិសុខសាន្ត។ រូបភាព សុវណ្ណភូមិ*

# មណ្ឌលសុខសាន្តផ្តល់ក្តីសង្ឃឹមដល់កុមារមានពិការភាព

អាគារថ្មីមួយខ្នង ដែលសម្ពោធដាក់ឱ្យប្រើប្រាស់សម្រាប់សកម្មភាពថែទាំកុមារមានពិការភាពនាព្រឹកថ្ងៃសុក្រទី ៥ ខែមេសា ឆ្នាំ២០១៩នេះ មាន៧បន្ទប់ គឺមានបន្ទប់ ព្យាបាលដោយចលនាមួយបន្ទប់សម្រួលអារម្មណ៍កុមារ១បន្ទាប់ថ្នាក់អប់រំពិសេសមួយ បន្ទប់ហាត់ភាសាមួយ បន្ទប់ការិយាល័យ បន្ទប់ដាក់សម្ភារៈ២ បន្ទប់ទឹក៣ និងអាងហែលទឹកសម្រាប់លំហាត់ប្រាណ និងព្យាបាលដោយចលនាមួយ។ អាគារថ្មីនេះ ជាអំណោយរបស់ក្រុមសប្បុរសជនបេសកកម្មកម្ពុជា (Mission Cambodge)។

រហូតមកដល់ពេលនេះមណ្ឌលភូមិសុខសាន្តបានទទួលកុមារមានពិការភាពចំនួន ៨៤នាក់ ក្នុងនោះកុមារដែលមានទទួលសេវាប្រចាំថ្ងៃមានចំនួនពី១៥ ទៅ២០នាក់ដោយទទួលព្យាបាលដោយចលនា ថែទាំសុខភាពអនាម័យ ទទួលអាហារបំប៉នជាដើម។ មណ្ឌលក៏មានបង្រៀនអក្សរលេខ និងបង្រៀនអំពីការរស់នៅប្រចាំថ្ងៃដល់កុមារផងដែរ។

លោកអភិបាលអូលីវីយេ ដែលជាស្ថាបនិកនៃមណ្ឌលសុខសាន្តមានប្រសាសន៍ថា ការកសាងអាគារថ្មីក្នុងមណ្ឌលសុខសាន្តនេះ គឺដើម្បីជួយផ្តល់ការថែទាំសុខភាពដល់កុមារមានពិការភាពនៅទីនេះ ឱ្យពួកគេទទួលបានក្តីស្រលាញ់ ការយកចិត្តទុកដាក់ និងការថែទាំសុខភាពបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងអប់រំពួកគេឱ្យមានចំណេះដឹង និងឈ្លាសវៃដូចកុមារធម្មតាដែរ។

មណ្ឌលភូមិសុខសាន្តបានបង្កើតឡើងដោយលោក អូលីវីយេ ជ្មិតអឺស្លែរ នៅដើមទសវត្សរ៍ឆ្នាំ២០០០ នៅភ្នំវល្លិ៍ ក្នុងខេត្តកំពតជាមួយក្រុមគ្រួសារ ដែលរស់នៅជាមួយមេរោគអេដស៍រហូតឆ្នាំ២០១០ បានប្តូរទីតាំងមកកាន់ភូមិពងទឹកខាងត្បូង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។ ប្រធានមណ្ឌលសុខសាន្តបានឱ្យដឹងថា សម្រាប់ទីតាំងថ្មីមានផ្ទះសម្រាប់គ្រួសាររស់នៅជាមួយមេរោគអេដស៍១០ខ្នង មត្តេយ្យសាលាតាមគរុកោសល្យម៉ុតេស្សូរី ផ្ទះស្នាក់នៅសម្រាប់សិស្សចំនួន២ខ្នង អាគារស្វាគមន៍ និងថែទាំកុមារមានពិការភាពចំនួន២ខ្នង រួមនិងអាគារមួយចំនួនដែលបម្រើដល់សកម្មភាពក្នុងមណ្ឌលភូមិសុខសាន្ត៕

## Peace Centre Provides Hope for disabled children

A seven room-building for child care was inaugurated on the morning of Friday 5 April 2019. The new building consisted of one physiotherapy room, one relaxation room, one special education, one language practice room, two storage rooms, three bathrooms and one swimming pool. The building was donated by Mission Cambodge.

Until now, the centre has received 84 children with disabilities. Of whom 15 to 20 had received the service of physiotherapy treatment, health care, personal hygiene and body-promotion food. The centre also teaches them on letters, numbers and also day-to-day life.

Bishop Olivier, who is also the founder of the Peace Centre, said that the new building was to help provide health care the disabled children here in order that they receive love, attention and technically proper health care and educate them with knowledge and intelligence as ordinary children.

The Peace Centre was established by bishop Olivier Schmitthaeusler in 2000 at the Phnom Voarh in Kampot province along with AIDS-Positive families until 2010 it was relocated to Kous commune's Pong Teuk village in Take province's Tramkak district. According to a report by Keo Phok, the director of the Peace Centre, for the new relocation, there are 10 houses for the AIDS-Positive families two Montessori method of education pre-schools for boarding. Two buildings for welcoming and caring for children with disabilities and a few buildings are for activities in the centre.





# ជំនួបសំណេះសំណាលជាមួយគ្រួសារអ្នកជំងឺអេដស៍



*លោកអភិបាលជួបសំណេះសំណាលជាមួយបងប្អូនដែលរងផលប៉ះពាល់ដោយសារមេរោគអេដស៍។ រូបភាព សុវណ្ណភូមិ*

លោកអូលីវីយេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានជួបសំណេះសំណាលជាមួយបងប្អូន អ្នកជំងឺ និងរស់នៅជាមួយមេរោគអេដស៍ចំនួន ១០០ គ្រួសារ នៅមន្ទីរធម្មការ និងសាសនាខេត្តតាកែវ នាឱកាសអបអរសាទរបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៩ ដោយមានកិច្ចសហការរវាងព្រះសហគមន៍កាតូលិក និងមន្ទីរធម្មការ និងសាសនាខេត្តតាកែវ។ បងប្អូនទាំង១០០គ្រួសារនេះមកពីតំបន់មួយចំនួននៅជុំវិញខេត្តតាកែវ។

ក្នុងនោះដែរ លោក គាំ ដាំផេង អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្តតាកែវថា ពិធីសំណេះសំណាលនេះជាសក្ខីភាពមួយបញ្ជាក់ពីការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ព្រះសហគមន៍កាតូលិក និងអរគុណដល់លោកអភិបាលអូលីវីយេដែលតែងតែចូលរួមយ៉ាងសកម្ម និងយកអំណោយចែកឱ្យអ្នកទាំងអស់គ្នានៅក្នុងខេត្តតាកែវប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

ក្នុងពិធីនេះ លោកអភិបាលអូលីវីយេបានមានប្រសាសន៍ថា នេះជាឱកាសមួយដើម្បីជូនពរដល់បងប្អូនទាំងអស់ឱ្យមានកម្លាំងចិត្តតស៊ូ និងមានសេចក្តីសុខជាប្រចាំ។ លោកថាបញ្ហារបស់យើងគឺជំងឺប្រចាំថ្ងៃ ហើយអ្វីដែលសំខាន់បំផុតគឺជីវិតរបស់យើងសព្វថ្ងៃដែលមានទាំងសុខ និងមានទុក្ខ។

លោកអភិបាលបានលើកទឹកចិត្តបន្តទៀតថា នៅក្នុងខេត្តតាកែវ យើងមានជាង ២ពាន់នាក់ដែលមានជំងឺនេះ ខ្ញុំបានអានព័ត៌មានគេបានបញ្ជាក់ថា ៥ ឆ្នាំទៀតនឹងមានវ៉ាក់សាំងការពារ ជំងឺអេដស៍ ប៉ុន្តែសំខាន់សូមឱ្យយើងប្រយ័ត្ន កុំឱ្យមានដៃគូថ្មីគឺមានប្រពន្ធតែមួយ និងប្រើប្រាស់ថ្នាំឱ្យបានទៀងទាត់។

ក្នុងឱកាសនេះដែរ លោកអភិបាល បានស្នើសុំ ដល់យាយៗដែលមានវត្តមាននៅទីនេះ ជួយអប់រំដល់យុវជនបន្តទៀត។ លោកបន្តថា៖ សន្តិភាពសំខាន់ណាស់ជាពិសេសនៅពេលដែលយើងចូលឆ្នាំថ្មីជាពេលវេលាដែលយើងជូនពរគ្នាទៅវិញទៅមក នៅពេលដែលទេវតាចុះនៅថ្ងៃអាទិត្យ យើងមានព្រះពរពីឋានលើមកមែន ប៉ុន្តែសូមកុំភ្លេចជូនពរគ្នាទៅវិញទៅមក។

លោកបញ្ជាក់ទៀតថា យើងរកឃើញសេចក្តីសុខនៅក្នុងជីវិតដោយចេះរួបរួមគ្នាជាគ្រួសារតែមួយ ចេះគោរពគ្នាជាបងប្អូន ហើយអ្វីដែលសំខាន់ទោះជាយើងសាសនាណាក្តី គឺជាបងប្អូន និងជាជនជាតិខ្មែរ ចេះស្រឡាញ់គ្នា កសាងជាតិដោយសមត្ថភាពរបស់យើងផ្ទាល់។

តាមប្រសាសន៍របស់លោក គាំ ដាំផេង បានឱ្យដឹងថាពិធីនេះប្រព្រឹត្តទៅដោយមានការសហការល្អពីព្រះសហគមន៍ និងមន្ទីរធម្មការ និងសាសនាខេត្ត តាកែវ។ ក្នុងពិធីនេះ អ្នកជំងឺក្នុងមួយគ្រួសារទទួលបានសាប៊ូដុសខ្លួន សាប៊ូលាងចាន សាប៊ូ បោកខោអាវ ទឹកត្រី ទឹកស៊ីអ៊ីវ អង្ករ និងថវិកាមួយចំនួន៕

## Bishop Olivier meets for Talks with Families who are AIDS-Positive

TWO students of the General Knowledge studies of the High School of St. Francois among the 12 Grade students received commendation certificates and consolation prizes for being outstanding students in Takeo province. They did their examinations along with other outstanding students across Takeo province and were ranked 7th. The Department of Education, Youth and Sports announced the results on March 7th 2019.

The awards presenting ceremony was held on 22 March 2019. Teacher and vice principal of the High School of St. Francois, Lay Makara, said that this was the third time the students of the high school had passed the nationwide examinations in order to enter the national exams. This year saw student Sem Sina passing the examination as an outstanding student in Literature and Pheaktra Chanchivy in Physics. The teacher continued by saying that the national examinations were held from 22-24 March 2019 in Siem Reap province. To encourage the two students, the school congratulated them by organising "best wishes" ceremony before setting off to enter the examinations.

The General Knowledge of the High School of St. Francois is a diploma educational establishment set up by the Catholic diocese of Phnom Penh in 2003 with Bishop Olivier Schmittaeusler as being the initiator and the founder. It is a high school in a remote area located in Kous commune's Chamkatieng village in Takeo province's Tramkak district.

The school has provided poor students nearby the opportunity to study.

The school has a clear curriculum, a library, a standard experimentation room, including capable teachers with a clear understanding of pedagogy.



*មេក្រុមកាយឫទ្ធិ ជាមួយសញ្ញាក្រុមដែលចូលរួមកម្មវិធីបោះជំរំនៅព្រះសហគមន៍ព្រះត្រៃឯក គិរីវង់ ខេត្តតាកែវ។*
*រូបភាព សុវណ្ណភូមិ*

# មេកាយឫទ្ធិត្រូវតែមានកម្លាំងដើម្បីបម្រើ

កាលពីថ្ងៃទី០៦ ដល់ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ កន្លងទៅនេះ ការិយាល័យយុវជនជំទង់ និងកុមារនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំកម្មវិធីបោះជំរំក្រុមកាយឫទ្ធិ នៅព្រះសហគមន៍ព្រះត្រៃឯកគិរីវង់ ខេត្តតាកែវ ដែលក្នុងនោះមានការចូលរួមពីលោកបូជាចារ្យ មេក្រុមកាយឫទ្ធិ និងកូនៗកាយឫទ្ធិ មកពីមណ្ឌលសកម្មភាពកំពង់សោម មណ្ឌលសកម្មភាពកំពត និងមណ្ឌលសកម្មភាពតាកែវ ជាង៤០០នាក់។

លោក ឡិឈឺផាន អេគួអាម ឆាលេស ជាបូជាចារ្យទទួលខុសត្រូវកម្មវិធីកាយឫទ្ធិភូមិភាគភ្នំពេញ បានថ្លែងក្នុងធម្មទេសនាបើកកម្មវិធីបោះជំរំនេះថា មេក្រុមកាយឫទ្ធិគឺជាការត្រាស់ហៅរបស់ព្រះជាម្ចាស់ ហើយមេក្រុមនេះមានកម្លាំងដើម្បីបម្រើកូនក្រុម និងត្រូវចេះថែរក្សាគេ។

លោកបន្តថា មេក្រុមកាយឫទ្ធិទទួលការអប់រំដើម្បីទៅបម្រើដោយមានព្រះពរពីព្រះជាម្ចាស់ដែលគង់នៅ ហើយនៅមុនពេលយើងធ្វើអ្វីមួយយើងត្រូវតែអធិដ្ឋានដើម្បីទូលអង្វរសុំកម្លាំងពីព្រះជាម្ចាស់។ ចុងក្រោយលោកក៏បានអធិដ្ឋាន សូមឱ្យមេកាយឫទ្ធិទាំងអស់មានកម្លាំងដែលមកពីព្រះជាម្ចាស់ ដើម្បីឱ្យគេមានកម្លាំងដើម្បីបម្រើ។

នៅក្នុងកម្មវិធីបោះជំរំនេះ មេក្រុមកាយឫទ្ធិទាំងអស់រិះគិតរួមគ្នាអំពីប្រធានបទរួមគឺខ្ញុំអាចធ្វើបាន ដោយមានបញ្ចូលល្បែងប្រជាប្រិយខ្មែរ គូររូប ការច្នៃប្រឌិត និងការចុះសួរសុខទុក្ខចាស់ៗនិងអ្នកក្រីក្រជាដើម។

លោក អារ៉ាងហ្គោ សាប៉ាតា ហ្វេរណាន់ដូ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍មណ្ឌលសកម្មភាពតាកែវ បានថ្លែងឱ្យដឹងថា៖ «សម្រាប់កម្មវិធីនេះមានផលប្រយោជន៍សម្រាប់កុមារ គ្រួសារ ព្រះសហគមន៍ និង សង្គម ព្រោះរបៀបទំនាក់ទំនងដែលយើងកំពុងតែមាន កំពុងតែបង្កើតរវាងគ្នានឹងគ្នា រវាងមនុស្ស និងធម្មជាតិ កាន់តែល្អប្រសើរឡើងៗ»។

លោកបន្តថា បន្ទាប់ពីបោះជំរំនេះហើយ កុមារទាំងអស់អាចយកទៅអនុវត្តក្នុងជីវិតរស់នៅ និងអាចរីកចម្រើននឹងចិញ្ចឹមជីវិតខាងផ្លូវកាយ និងផ្លូវវិញ្ញាណ។ លោកបញ្ជាក់ទៀតថា៖ «ឱ្យគាត់ដឹងថាពិតប្រាកដមែនជីវិតរបស់យើងមានតម្លៃដ៏ថ្លៃថ្នូរ នៅពេលយើងចាប់ផ្ដើមស្រឡាញ់ខ្លួនឯង ស្រឡាញ់បងប្អូនឯទៀតៗ ស្រឡាញ់ធម្មជាតិ នោះនាំឱ្យយើងចេះគោរពបងប្អូន និងធម្មជាតិ ដោយចេះថែរក្សា ធ្វើឱ្យមានការរីកចម្រើននិងអាចកសាងជីវិត និងព្រះរាជ្យរបស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងដែរ»។

កុមារី តុង លីនីតា ជាកូនកាយឫទ្ធិមកពីព្រះសហគមន៍សន្តប៉ូលកោះស្លារ បានប្រាប់ថា កម្មវិធីកាយឫទ្ធិរបស់ព្រះសហគមន៍បានធ្វើឱ្យរូបគេទទួលបាននូវភាពក្លាហាន ចេះគោរពចាស់ទុំ ដឹងគុណឪពុកម្ដាយ និងចេះស្រឡាញ់ធម្មជាតិជាដើម។ នីតាបន្តថាដោយសារហេតុនេះ ហើយទើបធ្វើឱ្យប៉ាម៉ាក់របស់គេសប្បាយចិត្ត ដោយមើលឃើញគេចេះកែខ្លួនល្អជាងមុន។

កម្មវិធីនេះបានជួយដល់នីតាជួបនិងស្គាល់គ្នាច្រើន ស្គាល់ពីភាពអត់ធ្មត់ និងភាពតស៊ូ នៅពេលចុះសួរសុខទុក្ខលោកតាលោកយាយ និងធ្វើឱ្យមានគំនិតចេះជួយអ្នកដទៃ៕

# Young Scouts Must Have Mental Strength to Serve

THE Pastoral Office for Youth, Teenagers and Children of the Catholic diocese of Phnom Penh, organised a camp from 6-9 April 2019 at the Holy Trinity Church in Kirivong, Takeo province. Participating in this camp were more than 400 young people under the leadership of priests, leaders and members of the young scouts in the pastoral sectors of Kampong Som, Kampot and Takeo.

Fr. Charles Ekuam Lechipan, the priest in charge of such camps of the diocese, said during his homily at the camp that the leaders of the scouts were the result of the call of God and these leaders had the strength to serve their members and also had to take care of them.

"The leaders of the young scouts receive education to serve the members with blessings from God who dwells in them and before we do something, we must pray petitioning for strength from God," said the priest.

In the end, he requested all the leaders to receive the strength from God in order for them to have the capacity to serve.

Fr. Fernando Arango, the parish priest of the Takeo provincial pastoral sector, said: "The programme is useful for the children, families, Church and society because the way of having relationships means establishing communion with each other and between human beings and nature."





# ២៤ម៉ោងសម្រាប់ព្រះជាម្ចាស់រួមជាមួយពិភពលោកទាំងមូល

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានរៀបចំអធិដ្ឋានពេញមួយយប់មួយថ្ងៃ មានឈ្មោះថា២៤ម៉ោងសម្រាប់ព្រះជាម្ចាស់។

លោកអភិបាលអូលីវីយេ ជ្មិតអីស្ល៊ែរបានជំរុញ និងយកចិត្តទុកដាក់យ៉ាងខ្លាំង ឱ្យគ្រប់មណ្ឌលសកម្មភាពព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញត្រូវរៀបចំការអធិដ្ឋាននេះ យកពេល២៤ម៉ោងសម្រាប់ព្រះជាម្ចាស់ ដើម្បីឆ្លើយតបទៅនឹងការអំពាវនាវរបស់សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលតម្រូវឱ្យព្រះសហគមន៍កាតូលិកនៅជុំវិញពិភពលោកនេះរៀបចំកម្មវិធីអធិដ្ឋាននេះនៅគ្រប់ភូមិភាគទាំងអស់។



*គ្រីស្តបរិស័ទអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្ត២៤ម៉ោងសម្រាប់ព្រះជាម្ចាស់នៅព្រះសហគមន៍សន្តីតេរេសាត្រែងត្រយឹង។*
*រូបភាព សុវណ្ណភូមិ*

កម្មវិធីនេះ ប្រារព្ធពិធីបើកនៅថ្ងៃទី៣០ ខែមិនា វេលាម៉ោង១២ថ្ងៃត្រង់ និងបិទបញ្ចប់ទៅវិញនៅថ្ងៃទី ៣១មិនា ខែវេលាម៉ោង១២ថ្ងៃត្រង់។ ព្រះសហគមន៍កាតូលិកនៃមណ្ឌលសកម្មភាពនីមួយៗអាចបើក និងបិទកម្មវិធី ព្រមទាំងចាត់ចែងកម្មវិធីអធិដ្ឋានពេញ២៤ម៉ោង។

នៅព្រះសហគមន៍កាតូលិក ព្រះវិហារសន្តម៉ាទីន ត្រែងត្រយឹង នៃមណ្ឌលសកម្មភាពខេត្តព្រះសីហនុ បានប្រារព្ធពិធីបើកដោយមានវត្តមានផ្ទាល់របស់លោកអភិបាលអូលីវីយេ ជ្មិតអីស្ល៊ែរ និងការចូលរួមពីសំណាក់លោកបូជាចារ្យទាំងអស់នៃមណ្ឌលសកម្មភាពព្រះសីហនុ ព្រមទាំងគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

មានប្រសាសន៍នៅក្នុងធម្មទេសនា លោកអភិបាល ព្រះសហគមន៍ភូមិភាគភ្នំពេញបានលើកឡើងថា យើងអធិដ្ឋានពេញមួយថ្ងៃមួយយប់ តបតាមការអញ្ជើញរបស់សម្ដេចប៉ាប និងយើងរួមបញ្ចូលគ្នាការអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ លើកទី៨១ ផងដែរ។ ព្រះសហគមន៍នៅកម្ពុជាតូច តែយើងរួមគ្នាជាមួយព្រះសហគមន៍ក្នុងពិភពលោកទាំងមូល ក្នុង២៤ម៉ោងសម្រាប់ព្រះជាម្ចាស់។

លោកអភិបាលបន្តថា៖ «ការអធិដ្ឋានឱ្យយើងបង្កើតរបៀបទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដើម្បីទទួលជំនឿ ទទួលសេចក្ដីសុខសាន្ត និងរស់នៅធ្វើសក្ខីភាពក្នុងសង្គម។ ពេលអធិដ្ឋានយើងមិនគ្រាន់តែនិយាយជាមួយព្រះជាម្ចាស់ តែយើងដាក់ខ្លួន ចំពោះព្រះភក្ត្រព្រះជាម្ចាស់ សូមព្រះអង្គមេត្តាករុណាចំពោះយើង»។

លោកបញ្ជាក់ថាពេលយើងអធិដ្ឋាន គឺស្ដាប់ព្រះជាម្ចាស់ ដោយបន្ទាបខ្លួន មានចិត្តស្មោះត្រង់ មានជំនឿលើព្រះអង្គជានិច្ច ដើម្បីឱ្យយើងចេះបម្រើបងប្អូនឯទៀតៗ ដោយសេចក្ដីស្រឡាញ់ និងដើម្បីនាំសេចក្ដីសុខសាន្តដល់ពិភពលោកទាំងមូល។ លោកថាគោលដៅរបស់យើងគឺ នាំឱ្យពិភពលោកនេះបានប្រកបដោយសេចក្ដីសុខសាន្ត៕

# Joining the world for 24 Hours for God

THE Catholic diocese Phnom Penh held a one-day and one-night of prayer called "24 hours for God".

Bishop Olivier Schmitthaeusler of the Apostolic Vicariate of Phnom Penh has focused great attention on all pastoral sectors of the diocese, in response to the call by Pope Francis requiring The worldwide Catholic Church to organise prayer services in all dioceses.

The service was held on 30 March at noon and concluded on 31 March, the following day at noon. Each parish should organize a similar 24-hour prayer service.

St. Martin's Church in Treng Traryeng of the Preah Sihanouk provincial pastoral sector held the prayer service led by bishop Olivier Schmitthaeusler. The service was attended by all priests of the sector and a large number of Catholics. In his homily, the bishop said: "We pray for a full day and night at the invitation of the Holy Father and we are united in the full night prayer, including praying for vocations for the 81st time. The Catholic Church in Cambodia is small, but we are united with the whole universal Church for 24 hours in prayer to God."

"Prayer enables us to communicate with God in an effort to receive the faith, peace and to live as testimonial witnesses in society. When praying, we not only speak with God, but also we are humble in the sight of God to be merciful on us," the Prelate said.

"When we pray, we listen to God with humility, sincerity, and with faith in Him always so that we could serve other people with love and to show peace to the whole world. Our goal is to bring this peace in this world," he emphasised.

# ប្រសិទ្ធីពរប្រេងនៃព្រះសហគមន៍កាតូលិកកម្ពុជា

គ្រីស្តបរិស័ទកាតូលិកមកពីភូមិភាគភ្នំពេញ បាត់ដំបង និងកំពង់ចាមជាច្រើនរយនាក់ និងបូជាចារ្យកាតូលិកទាំងអស់ នៅកម្ពុជា បានប្រារព្ធអភិបូជាប្រសិទ្ធីពរលើប្រេងសម្រាប់ព្រះសហគមន៍ទាំងអស់ឱ្យធ្វើជាសាក្សីនៃព្រះយេស៊ូ ដែលជាប្រពៃណីព្រះសហគមន៍កាតូលិក ក្រោមអធិបតីភាព លោកអភិបាលនៃព្រះសហគមន៍ទាំងបីភូមិភាគ រួមជាមួយអស់លោកបូជាចារ្យទាំងអស់ ដែលនៅក្នុងប្រទេសកម្ពុជា នាល្ងាចថ្ងៃទី៩ មេសា ២០១៩ នៅព្រះវិហារសន្តសិលានិសន្តប៉ូល មណ្ឌលសកម្មភាពភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី។



*មេក្រុមកាយឫទ្ធិ ជាមួយសញ្ញាក្រុមដែលចូលរួមកម្មវិធីបោះជំរំនៅព្រះសហគមន៍ព្រះត្រៃឯក គិរីវង់ ខេត្តតាកែវ។* *រូបភាព សម្បត្តិ*

នៅពេលតំណាងគ្រីស្តបរិស័ទ និងជាតំណាងគណៈកម្មាធិការសំខាន់ទាំងបីមានគណៈកម្មការពិធីបុណ្យ គណៈកម្មការសង្គហៈ និងគណៈកម្មការអប់រំជំនឿ ក្នុងព្រះសហគមន៍កាតូលិក បានហែថូប្រេងទាំងបីប្រភេទចូលមកក្នុងអង្គពិធី ដោយមានលោកអភិបាលនីមួយៗចាំទទួល និងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ទៅតាមប្រភេទនៃប្រេងដែលត្រូវប្រើស្របតាមប្រពៃណីនៃព្រះសហគមន៍កាតូលិកផងដែរ។

លោកអភិបាលអូលីវីយេ បានផ្លុំលើប្រេងទាំងនេះ ដើម្បីបញ្ជាក់ថាព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និងអធិដ្ឋានដោយនឹកដល់អគ្គសញ្ញានានា នឹកដល់ឫទ្ធិបារមីនៃប្រេងពិសិដ្ឋនៅក្នុងសម្ពន្ធមេត្រីចាស់ នឹកដល់ព្រះយេស៊ូដែលបំពេញបេសកម្មសង្គ្រោះមនុស្សលោក ហើយទូលអង្វរព្រះជាម្ចាស់ដល់ព្រះសហគមន៍ ដើម្បីបន្តបេសកម្មតាមរយៈប្រេងពិសិដ្ឋនេះ ដើម្បីឱ្យមនុស្សលោកបានទទួលព្រះពរ និងទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ដែលបានកើតជាថ្មីដោយអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញានានាដែលបានប្រើដោយប្រេងនេះ។

តាមប្រសាសន៍របស់លោកអភិបាលអូលីវីយេបានបញ្ជាក់ថា ប្រេងដែលបានធ្វើប្រសិទ្ធីពរនោះមានបីយ៉ាង គឺ៖ ១) ប្រេងសម្រាប់លាប ដើម្បីផ្តល់កម្លាំងឱ្យអ្នកជម្ងឺចាស់ជរា ជនពិការ និងអស់អ្នកដែលរងទុក្ខលំបាក។ ២) ប្រេងសម្រាប់អ្នករៀបចំខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក និងអស់អ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូ។ ៣) ប្រេងគ្រីស្មា ដែលប្រើសម្រាប់ អគ្គសញ្ញាលាបថ្ងាសសម្រាប់អស់អ្នកដែលស្ម័គ្រចិត្តថ្វាយខ្លួនជាអ្នកបម្រើព្រះជាម្ចាស់ សម្រាប់នឹស្សិតទេវវិទ្យាល័យ អគ្គសញ្ញាតែងតាំងជាបូជាចារ្យជាអភិបាល និងសម្រាប់ទីសក្ការៈនានានៃព្រះសហគមន៍ទាំងអស់ដើម្បីធ្វើជាសាក្សីនៃព្រះយេស៊ូ។

លោកថាមានតែលោកអភិបាលទេដែលមានសិទ្ធិប្រសិទ្ធិពរប្រេងទាំងនោះបាន ដោយសូមព្រះជាម្ចាស់គង់នៅជាមួយព្រះសហគមន៍ ដែលជាមូលហេតុមានបងប្អូនមកពីតំណាងព្រះសហគមន៍ទាំងអស់។

ពិធីនេះតែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំក្នុងរដូវអប់រំពិសេស មុនចូលក្នុងសប្តាហ៍ពិសិទ្ធ ដើម្បីយកទៅប្រើប្រាស់ក្នុងពិធីផ្សេងៗរបស់ព្រះសហគន៍ពេញមួយឆ្នាំ៕

## CHRISM MASS IN CAMBODIA

BISHOP Oliver Schmitthaeusler, the two Apostolic Prefects, priests, parishioners of the Catholic Church of Cambodia assembled to celebrate the Chrism Mass which also serves as a witness of Jesus. This is a tradition of the Catholic Church. The Chrism Mass was attended by a large number of parishioners from three dioceses of Battambang, Kampong Cham and Phnom Penh on the evening of 9 April 2019 at the Chapel of Sts. Peter and Paul in the Phnom Penh Thmei pastoral sector.

The three Liturgical committees also joined in the procession of carrying jars of Olive oil mixed with fragrant balsam towards the bishop who was waiting to receive them. Upon receiving the oils, the bishops prayed asking God to bless the oils to be used in administering the sacraments in accordance with the Tradition of the Catholic Church.

Bishop Oliver Schmitthaeusler of the Apostolic Vicariate of Phnom Penh blew on these oils while mixing it to signify that the Holy Spirit has come into the world. The bishop prayed recollecting sacraments and the Powers of the sacred Chrism in the New Testament. The bishop recollected the life of Jesus, who had fulfilled His Mission to save mankind and made intercession for the Church to continue its mission through this sacred Chrism. It is hoped that mankind would receive blessings and become the children of God, who have been renewed by baptism and sacraments, especially by this Chrism.

The bishops and all priests laid their hands on the Chrism asking God and the Powers of the Holy Spirit to enable the Chrism to become a sacrament that shows the Mercy of God saying 'May this Chrism be filled with the Holy Spirit and may it bring peace to those who receive it.'

Bishop Olivier stressed that the blessed Chrism consists of three types. The first was used for Baptism, Confirmation, Holy Orders and for the dedication of churches and Altars. The second is used for anointing the sick for strength and courage and the third, to anoint catechumens.

The Chrism is used for Confirmation for those who are willing to offer themselves to serve God, for seminarians, Holy Orders and the dedication of churches and Altars to bear witness to Jesus.

He further stressed only bishops who have the privilege to bless the Chrism by petitioning God to dwell in the Church, which was the reason why there were brothers and sisters representing all the Churches.

The Chrism Mass is celebrated every year during the Lenten season before entering Holy Week in order for the Chrism to be taken for use in liturgical services in the parishes for the whole year.





# បេក្ខជនជាង១៥០នាក់ ត្រៀមខ្លួនជាសមាជិកក្នុងព្រះសហគមន៍កាតូលិក



*បេក្ខជនជំហានទីពីរដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងបុណ្យចម្លង។* *រូបភាព សុវណ្ណភូមិ*

បេក្ខជន ១៥៤នាក់ មកពីមណ្ឌលសកម្មភាពទាំង ៩ នៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ធ្វើសំណាក់ធម៌ដើម្បីរៀបចំខ្លួន មុននឹងទទួលជំហានទីពីរ នៃអគ្គសញ្ញាជ្រមុជទឹក នាថ្ងៃបុណ្យចម្លង ណែនាំ លោកអភិបាលអូលីវីយេ ជ្មិតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នាថ្ងៃទី ៩ ខែមីនា និងទទួលពិធីត្រាស់ហៅ (ជំហានទី២) នៅថ្ងៃទី១០ មីនា នៅព្រះវិហារសន្តប៉ូល និងសន្តសិលា ភ្នំពេញថ្មី។

បេក្ខជនទាំងអស់ត្រូវបានលោកអភិបាលអូលីវីយេហៅឈ្មោះ ដើម្បីឱ្យពួកគាត់បង្ហាញខ្លួននៅមុខព្រះសហគមន៍ និងប្រកាសថា ពួកគាត់នឹងទទួលអគ្គសញ្ញាជ្រមុជទឹកនៅថ្ងៃបុណ្យចម្លងខាងមុខ។

លោកអភិបាលបានដាស់តឿនអ្នកចូលរួមទាំងអស់ ឱ្យឈ្វេងយល់អំពីព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះបិតា ចំពោះមនុស្សទាំងអស់។ ជាងនេះទៅទៀត លោកអភិបាលព្រះសហគមន៍ ក៏បានរំលឹកបេក្ខជនទាំងអស់ត្រូវបង្ហាញសក្ខីភាពជាចម្បង ដោយ៖ ១) ជំនឿលើព្រះគ្រីស្ត ធ្វើជាខែល ឬជាអាវពន្លឺ។ ២) យកព្រះបន្ទូលដែលជាសេចក្តីពិតមកក្រវាត់ចង្កេះ។ ៣)ចូរអធិដ្ឋានគ្រប់ពេលវេលា ធ្វើជាមួកការពារ។ ៤) លើកលែងទោស មកធ្វើជាវ៉ែនតា។ ដូចព្រះអម្ចាស់បែរព្រះភក្ត្រទតមកលោកសិលា។ ៥) សេចក្តីស្រឡាញ់ធ្វើជាស្រោមដៃ។ អ្នកឯទៀតៗ ដោយនឹកដល់វិន័យរបស់ព្រះយេស៊ូ «ត្រូវស្រលាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រលាញ់អ្នករាល់គ្នាដែរ។ ៦) សេចក្តីក្លាហានជាទ្រនាប់ជើង គឺយកចិត្តប្រុងប្រៀបផ្សាយដំណឹងល្អអំពីសេចក្តីសុខសាន្ត មកពាក់ជាស្បែកជើង។

តាមលោកអភិបាលអូលីវីយេ ព្រះសហគមន៍ប្រារព្ធពិធីត្រាស់ហៅបេក្ខជនជាឱឡារិក ក្នុងពេលចាប់ផ្តើមរដូវត្រណមនេះ ដើម្បីឱ្យគេមានពេលតាមសប្តាហ៍នីមួយៗ រៀបចំខ្លួនតាមដំណាក់កាលនៃកម្មវិធីអប់រំជំនឿកាតូលិក៕

## MORE THAN 150 CANDIDATES TAKE THE SECOND STEP FOR BAPTISM

ONE hundred and fifty four candidates from nine parishes of the Catholic diocese of Phnom Penh attended a retreat in preparation for taking the second step (a formal call to be baptised during Easter Sunday). The retreat was led by bishop Olivier Schmitthaeusler of the Apostolic Vicariate of Phnom Penh on 9 March 2019 where they were called to take the second step on 10 March 2019 at the Chapel of Sts. Peter and Paul in Phnom Penh Thmei.

The bishop called each candidate by name to appear in front of the congregation and profess that they would receive the sacrament of baptism during the forthcoming Easter celebrations.

The bishop advised all of them to learn about the abundant love of the Father for all humankind. More than that, the Prelate also reminded them to express their testimony of witness about their faith:

First, believe in the Bible as a shield and light. Second, take the Word of God as the truth to tie around the waist. Third, pray all the time. Fourth, forgive and turn to be a mirror, just as the Lord turn His Face to Peter. Fifth, love is like the fingers: love other people by contemplating the laws of Jesus: 'Love others just as I love you' and sixth, the courage like the soles of the feet, that is, be prudent to spread the Gospel of peace like wearing shoes.

The Church observes the solemnities of such a great occasion for the candidates in the season of Lent so that they will have time each week to read and be well-prepared in a phase of the Catholic programme of education.

# ព្រះសហគមន៍កាតូលិកនៅកម្ពុជា ខ្វះអ្នកបួស

នៅក្នុងពិធីអធិដ្ឋានសម្រាប់ការត្រាស់ហៅលើកទី៨៣ នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ៉ (ចំប៉ា) នៃមណ្ឌលសកកម្មភាពមេគង្គ លោកអភិបាលអូលីវីយេ ជ្មីតអឺស្លែរ ស្នើសុំឱ្យមានការអធិដ្ឋានបន្ថែមទៀត សម្រាប់ជីវិតជាអ្នកបួស ដើម្បីបម្រើដល់ព្រះសហគមន៍។ លោកមានប្រសាសន៍ថា៖ «យើងត្រូវការបព្វជិត បព្វជិតា ដើម្បីបម្រើបងប្អូនទាំងអស់ឱ្យចូលទៅក្នុងជីវិតថ្មីនេះ»។



*លោកអភិបាលអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្តនៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេចំប៉ា។ រូបភាព សុវណ្ណភូមិ*

នៅក្នុងធម្មទេសនានេះដែរ លោកអភិបាលអូលីវីយេ បានបញ្ជាក់ថា សព្វថ្ងៃព្រះសហគមន៍នៅខ្វះបូជាចារ្យ និងបងស្រី។ ដូច្នេះហើយ លោកអភិបាលបានអំពាវនាវដល់យុវជន យុវនារីឱ្យស្ម័គ្រចិត្ត ដើម្បីបម្រើព្រះសហគមន៍ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់។

លោកអភិបាលបានឱ្យដឹងថា មុខងារជាបូជាចារ្យមានសារៈសំខាន់ណាស់សម្រាប់ព្រះសហគមន៍ ដោយសារ«តាមរយៈអគ្គសញ្ញានានា បានធ្វើឱ្យគ្រីស្តបរិស័ទចូលទៅក្នុងជីវិតថ្មីដែលបានទទួលការសង្គ្រោះ»។

លោកអភិបាលក៏បានជំរុញដល់គ្រីស្តបរិស័ទទាំងអស់ឱ្យចេះលើកទឹកចិត្តកូនចៅ ដើម្បីក្លាយទៅជាបព្វជិត បព្វជិតា និងអប់រំកូនៗឱ្យចេះអធិដ្ឋាន ស្រឡាញ់ព្រះយេស៊ូ ស្រឡាញ់ព្រះនាងម៉ារី និងចូលព្រះវិហាររៀងរាល់អាទិត្យ ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូ ព្រមទាំងចេះគោរពចាស់ទុំ និងបព្វជិតបព្វជិតា។ ក្នុងនោះដែរលោកក៏បាន ដាស់តឿនយុវជនយុវនារីឱ្យចេះគិតអំពីអនាគតរបស់ខ្លួន និងអនាគតរបស់ព្រះសហគមន៍ផងដែរ។

កម្មវិធីអធិដ្ឋាននេះបានធ្វើឡើងនៅភូមិចំប៉ា ស្រុកកៀនស្វាយ ខេត្តកណ្តាល នាថ្ងៃទី២ ឧសភា ២០១៩ ដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។ ជារៀងរាល់មួយខែម្តងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រៀបចំកម្មវិធីនេះ នៅតាមមណ្ឌលកម្មភាពនានា ដោយអធិដ្ឋានពេញយប់ ដើម្បីការត្រាស់ហៅនៅក្នុងប្រទេសកម្ពុជា៕

## CAMBODIA CATHOLIC CHURCH STILL HAS A SHORTAGE OF RELIGIOUS MEN/WOMEN

DURING a night of prayer for vocations for the 83rd time at St. Francis Xavier's church (Wat Champa) in the pastoral sector of the Mekong River, Bishop Olivier Schmitthaeusler of the Apostolic Vicariate of Phnom Penh requested that additional prayers be held for religious life in the service of the local Church. He said: "We need the clergy to serve all brothers and sisters going into renewed life."



During his homily, Bishop Olivier stressed that today the Church has still fallen short of priests and nuns. The bishop therefore called on Catholic youth to volunteer to serve the Church, who are the People of God.

The bishop said that priestly functions have extreme importance for the Church "Sacraments make Catholics enter into renewed life receiving salvation."

He has also urged all Catholics to encourage their children to become religious and educate them to pray, love Jesus and the Blessed Virgin Mary and attend church services every Sunday to connect with Jesus, respect the elderly and the clergy. He advised youth to think of their future and also of the Church.

This prayer service was held on 2nd May 2019 in Kien Svay district's Champa village in Kandal province, with a large number of the Catholics in attendance. Once a month, the Catholic Diocese of Phnom Penh holds a night of prayer for vocations at various pastoral sectors.





## សកម្មភាពលោក អូលីវីយេ ជ្មីតអឺស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ខែ មិថុនា ឆ្នាំ២០១៩

| | |
|---|---|
| ១ មិថុនា | ៖ ទិវាកុមារអន្តរជាតិ នៅព្រះសហគមន៍ចំប៉ា និងនៅព្រះសហគមន៍សន្តប៉ូល សន្តសិលា ភ្នំពេញថ្មី |
| ២ មិថុនា | ៖ អគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍អរិយក្សត្រ |
| ៣-៨ មិថុនា | ៖ សំណាក់ធម៌បូជាចារ្យទូទាំងប្រទេសនៅកំពង់សោម |
| ៩ មិថុនា | ៖ អភិបូជាអន្តរជាតិសម្រាប់បុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក និងអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច |
| ១១ មិថុនា | ៖ ប្រជុំជាមួយបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាព និងប្រជុំជាមួយអ្នកទទួលខុសត្រូវទូទៅខាងហិរញ្ញវត្ថុរបស់សាសនទូតក្រុម MEP |
| ១៣ មិថុនា | ៖ ប្រជុំក្រុមប្រឹក្សាបេសកកម្ម |
| ១៤ មិថុនា | ៖ ប្រជុំជាមួយអ្នកទទួលខុសត្រូវសេវាសុខភាព និងអង្គការសម្រាប់ជនពិការភាព |
| ១៦ មិថុនា | ៖ អគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍បឹងទំពុន |
| ១៧ មិថុនា | ៖ ប្រជុំជាមួយប្រធានមន្ទីរពេទ្យ Bambino Gesu Roma |
| ២២ មិថុនា | ៖ ពិធីជប់លៀងនៅព្រះសហគម៏ចំការទៀង |
| ២៣ មិថុនា | ៖ អភិបូជានៅព្រះសហគមន៍ចំការទៀង |
| ២៤-២៦ មិថុនា | ៖ ខ្សែវីឌីអូអំពីជីវិតពិត |
| ២៧ មិថុនា | ៖ ប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការការីតាស ម៉ោង៦ល្ងាចពិធីបិទវគ្គនៅទេវវិទ្យាល័យ |
| ២៨ មិថុនា | ៖ ការសួរសុខទុក្ខផ្លូវការនៅអារ៉ាមការ៉ែល |
| ២៩ មិថុនា | ៖ ម៉ោង៨:៣០ព្រឹកសំណាក់បូជាចារ្យ និង ម៉ោង១០ព្រឹក អភិបូជាបុណ្យសន្តសិលា និងសន្តប៉ូលនៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច ពិធីជប់លៀងលាលោកឪពុកប៉ប ពីសេ្ស ពិធីខួបតែងតាំងជាបូជាចារ្យ |
| ៣០ មិថុនា | ៖ អគ្គសញ្ញាលាបថ្ងាស និងប្រសិទ្ធិពរជួងនៅព្រះសហគមន៍បឹងឈូក |

## The Activities of Bishop Olivier SCHMITTHAEUSLER, MEP Apostolic Vicar of Phnom Penh in June 2019

| | |
|---|---|
| 1 June | : International Children Day at Champa and Phnom-Penh Thmey |
| 2 June | : Confirmation at Areyksat |
| 3-8 June | : Retreat for all clergy at Kompong Som |
| 9 June | : International Mass of Pentecost and Confirmations at Saint Joseph Parish |
| 11 June | : Meeting with priests in charge of pastoral sector and MEP General Procureur. Financial matters |
| 13 June | : Mission Council |
| 14 June | : Meeting with Health Service and NGO working for persons with handicap |
| 16 June | : Confirmations at Boueng Toumpun Parish |
| 17 June | : Meeting with President of Bambino Gesu Roma |
| 22 June | : Special Party at Chomkatieng |
| 23 June | : Holy Sacrament Mass and Procession at Chomkatieng |
| 24-26 June | : Video: A real life.... |
| 27 June | : Caritas Board, 6pm Closing Year at Major Seminary |
| 28 June | : Canonical visit at Carmel |
| 29 June | : 8:30am priest recollection and Holy Mass of solemnity of Saint Peter and SAINT Paul (10am) at Saint Joseph Parish. Farwell of Father Bob Piché, Jubilee of priests ordination |
| 30 June | : Confirmation and blessing of Bell at Boeung Chhouk Parish |

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

## ចំការទៀង ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៩

## *ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ា!*

អត្ថបទទី១៖ កក ១០,៣៤.៣៧-៤៣
អត្ថបទទី២៖ កូឡ ៣,១-៤
ដំណឹងល្អ៖ យហ ២០,១-៩

*បងប្អូនជាទីស្រឡាញ់!*

យប់នេះ ខ្ញុំមានអំណរសប្បាយក្នុងការចែករំលែក ធម្មទេសនានៅក្នុងភូមិភាគភ្នំពេញទាំងមូល។ យប់មិញនៅព្រែកប្បាស យើងបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់បងប្អូន១៨នាក់ នៅព្រះសហគមន៍គិរីវង់យើងមាន៥នាក់ និងនៅប៉ុន្មានកន្លែងក្នុងភូមិភាគភ្នំពេញយើងមានព្រះសហគមន៍នីមួយៗដែលបានធ្វើពិធីជ្រមុជទឹក។ យប់នេះ ខ្ញុំមានអំណរសប្បាយទទួលស្វាគមន៍បងប្អូន៥៥នាក់ ដែលមកពីព្រះសហគមន៍សន្តិម៉ារីញញឹមនេះ មកពីព្រះសហគមន៍ថ្មីៗនៅត្រពាំងក្រញូង (ជាលើកទីមួយដែលមានពិធីជ្រមុជទឹក) មកពីព្រះសហគមន៍ឡូមខេត្តតាកែវ និងមកពីព្រះសហគមន៍សន្តប៉ូល។ យប់នេះជាអំណរសប្បាយសម្រាប់ព្រះសហគមន៍នៅក្នុងខេត្តតាកែវ និងសម្រាប់ព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ដែលព្រះជាម្ចាស់បានជ្រើសរើស៥៥នាក់ថែមទៀត ដើម្បីទៅជាបុត្រាបុត្រីរបស់ព្រះអង្គ និងជាពិសេសដើម្បីចូលរួមនៅក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់ ដែលជាព្រះសហគមន៍។

**នៅទីនេះយើងមានឈើឆ្កាង** ពីប៉ុន្មានថ្ងៃហើយដែលយើងគោរពព្រះយេស៊ូសោយទីវង្គត។ នៅពេលយើងនឹកឃើញព្រះយេស៊ូនៅលើឈើឆ្កាង នៅក្នុងដួងចិត្តរបស់យើង នៅក្នុងជីវិតរបស់យើងគឺយើងសោកស្តាយ យើងឈឺចិត្តដែរ។ បងប្អូនមួយចំនួនដែលបានចូលរួមនៅក្នុងពិធីគោរពឈើឆ្កាង បានក្រាបថ្វាយបង្គំនៅឈើឆ្កាងនេះ ដែលព្រះបុត្រារបស់ព្រះជាម្ចាស់ បានសោយព្រះទីវង្គត ហើយនៅពេលនោះយើងបានបន្ទាបខ្លួនឱនកាយ ដើម្បីថើបព្រះបាទារបស់ព្រះយេស៊ូ ដែលបានបូជាជីវិតសម្រាប់យើង។ មានបងប្អូនច្រើនបានឆ្ងល់ថា មូលហេតុអ្វីបានជាគ្រីស្តបរិស័ទគោរពព្រះយេស៊ូដែលសោយព្រះទិវង្គតនៅលើឈើឆ្កាង? មូលហេតុអ្វីបានជាគ្រីស្តបរិស័ទក្រាបថ្វាយបង្គំ និងថើបឈើឆ្កាងដោយមានព្រះជីវិតសុទ្ធដែលសោយព្រះទីវង្គត?

**នៅពេលយើងនៅក្បែរឈើឆ្កាង** នៅពេលនោះយើងនឹកឃើញ ដល់ទុក្ខលំបាកនៃជីវិតរបស់យើង យើងនឹកឃើញពីជីវិតរបស់យើងជួនកាលនៅក្នុងភាពងងឹត និងជីវភាពក្រីក្ររបស់យើង យើងនឹកឃើញដល់កូនក្មេងមានកូនក្មេងប៉ុន្មាននាក់នៅលើទឹកដីយើង ដែលអត់មានសមត្ថភាពទៅរៀនសូត្រ ដែលអត់មានសមត្ថភាពទៅមន្ទីរពេទ្យនៅពេលគេឈឺ។ យើងនឹកឃើញដល់ស្ត្រីមេម៉ាយ ដែលប្តីបោះបង់ចោលឬប្តីស្លាប់។ យើងនឹកឃើញដល់អ្នកដែលអត់មានម្ហូបគ្រប់គ្រាន់ ដើម្បីឱ្យកូនរបស់គេញ៉ាំឆ្អែត។ យើងនឹកឃើញដល់ពេលដែលយើងចាស់ជរា អត់មានអ្នកទីពឹងដើម្បីលើកទឹកចិត្តយើង។ យើងអាចនឹកឃើញរឿងច្រើននៅក្នុងជីវិតរបស់យើង ដែលណែនាំឱ្យយើងពិបាក ជំងឺដែលយើងមាន ទុក្ខលំបាកដែលយើងមាន ការឈឺចាប់ដែលយើងមាន និងនៅពេលដែលយើងឃើញឈើឆ្កាងរបស់ព្រះគ្រីស្ត ហើយនៅពេលដែលយើងបានថ្វាយបង្គំនៅមុខឈើឆ្កាងនេះ។

**នៅពេលយើងមើលឈើឆ្កាង** យើងនឹកឃើញដល់ទីក្រុងប៉ារីស ដែលប៉ុន្មានថ្ងៃមុនវិសាលវិហារបានឆេះ យើងបានឃើញវិហាររបស់ព្រះជាម្ចាស់ដែលកំពុងត្រៀមខ្លួន ដើម្បីថ្វាយអភិបូជាសម្រាប់ព្រះពរលើប្រេងពិសិដ្ឋនៅថ្ងៃព្រះយេស៊ូសោយទីវង្គត នៅថ្ងៃដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះវិហារនេះបានឆេះពេញមួយយប់។ អណ្តាតភ្លើងនេះណែនាំឱ្យយើងភ្ញាក់ស្មារតី និងសួរសំណួរនៅក្នុងដួងចិត្តរបស់យើងថា **តើយើងបានធ្វើអ្វីដល់ព្រះជាម្ចាស់? តើយើងចេះគោរពព្រះជាម្ចាស់ពិតមែនឬ? តើយើងស្រឡាញ់ព្រះជាម្ចាស់ពិតមែនទេ? តើយើងចេះយកព្រះជាម្ចាស់ជាអតិភាពនៅក្នុងជីវិតរបស់យើងឬទេ?**

យើងមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ យប់នេះជាយប់នៃសេចក្តីសង្ឃឹម យើងដឹងថាគ្រប់ភាពងងឹតដែលយើងបានផ្ញើទៅលើព្រះឈើឆ្កាងរបស់ព្រះយេស៊ូ យប់នេះភាពងងឹតនេះពោរពេញដោយសេចក្តីសង្ឃឹម ពោរពេញដោយពន្លឺថ្មី គឺពន្លឺនៃជីវិតដែលយើងបានឃើញអំបាញ់មិញផ្ទាល់ភ្នែក ពន្លឺដែលណែនាំឱ្យជីវិតរបស់យើងទៅជាជីវិតថ្មី ណែនាំឱ្យបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹកយប់នេះដឹងថាបន្តិចទៀតគេកើតសារជាថ្មី ណែនាំឱ្យយើងអរព្រះគុណព្រះជាម្ចាស់ និងណែនាំឱ្យយើងភ្ញាក់ស្មារតី។ ជាពិសេស ដើម្បីណែនាំឱ្យយើងដឹងច្បាស់ថា គ្រប់ភាពងងឹតមានផ្កាយដ៏តូចមួយដែលបំភ្លឺផ្លូវ ផ្កាយដែលបានណែនាំហោរាចារ្យទៅថ្វាយបង្គំព្រះយេស៊ូប្រសូត។ នៅក្នុងភាពងងឹតនៃជីវិតរបស់យើង មានអណ្តាតភ្លើងដ៏តូចមួយដែលណែនាំឱ្យយើងដឹងថា ខ្ញុំមានមិត្តភក្តិ ខ្ញុំមានគ្រីស្តបរិស័ទ ខ្ញុំមានព្រះយេស៊ូគ្រីស្តដែលជាទីពឹងរបស់ខ្ញុំ ដែលចាប់ដៃខ្ញុំជាកុមារកំព្រា ជាស្ត្រីមេម៉ាយ ជាចាស់ជរា ជាអ្នកគ្មានទីពឹង ជាអ្នកក្រីក្រដែលដាច់ពេល យប់នេះយើងដឹងថាព្រះយេស៊ូចាប់ដៃរបស់យើង ដើម្បីឱ្យយើងធ្វើដំណើរតទៅទៀត ដើម្បីមានសេចក្តីស្រឡាញ់ និងសេចក្តីសង្ឃឹមនៅក្នុងជីវិត **កុំខ្លាចអី! ព្រះយេស៊ូគង់នៅជាមួយយើង**។

នៅពេលខ្ញុំមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូដែលបំភ្លឺយប់នេះ ខ្ញុំនឹកឃើញដល់សង្គ្រាមដល់ភេរវកម្ម ដល់របៀបដែលគេបំផ្លាញគ្រីស្តបរិស័ទ ដល់របៀបដែលគេសម្លាប់មនុស្សនៅប៉ុន្មានប្រទេស យើងជាប្រជារាស្ត្ររបស់ព្រះនៃសេចក្តីសង្ឃឹម យើងជាគ្រួសារមួយយ៉ាងពិសេសដែលមានសមត្ថភាព ដើម្បីបង្កើតភាតរភាពនៅក្នុងពិភពលោក។ ដូច្នេះ មនុស្សដែលចង់សម្លាប់អ្នកដទៃ មនុស្សដែលចង់ធ្វើបាបអ្នកដទៃមិនអាចឈ្នះទេ ដោយសារមានតែភាតរភាព មានន័យថាយើងជាបងប្អូនគ្នា យើងជាមនុស្សដែលចេះលើកទឹកចិត្តគ្នា យើងជាគ្រួសារមួយយ៉ាងធំដែលចេះស្រឡាញ់គ្នា។
**នៅពេលខ្ញុំមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ** ខ្ញុំនឹកឃើញវិសាលវិហារនៅទីក្រុងប៉ារីសដែលបានឆេះ ប៉ុន្តែខ្ញុំនឹកឃើញដល់ព្រះជាម្ចាស់ដែលមិនបានលះបង់ចោលប្រជារាស្ត្ររបស់ព្រះអង្គ។ ប៉ុន្តែព្រះជាម្ចាស់ណែនាំឱ្យយើងភ្ញាក់ស្មារតី កុំឱ្យយើងបោះបង់ទំនាក់ទំនងជាមួយព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង កុំឱ្យយើងបាត់បង់ជីវិតខាងផ្លូវវិញ្ញាណ កុំឱ្យយើងគិតតែពីភាពអាត្មានិយម កុំឱ្យយើងគិតអំពីសុខមាភាពផ្ទាល់ខ្លួនតែប៉ុណ្ណឹង ប៉ុន្តែព្រះជាម្ចាស់ណែនាំឱ្យបេះដូងរបស់យើង ភ្នែករបស់យើង ដួងចិត្តរបស់យើងបើកចំហរយ៉ាងធំណាស់ ដើម្បីស្រឡាញ់ ដើម្បីមានជីវិតថ្មី ដោយសារយប់នេះយើងកើតជាថ្មីតាមផ្លូវវិញ្ញាណ នៅក្នុងទឹកនិងនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ អណ្តាតភ្លើងដែលយើងបានឃើញនៅលើដំបូលនៃវិសាលវិហារនៅទីក្រុងប៉ារីស ប្រហែលណែនាំឱ្យគ្រីស្តបរិស័ទនៅក្នុងពិភពលោកទាំងមូលភ្ញាក់ស្មារតីសារជាថ្មី នឹងគិតផ្ទាល់ខ្លួនជំនឿរបស់ខ្ញុំទៅដល់ណា សេចក្តីស្រឡាញ់របស់ខ្ញុំចំពោះព្រះជាម្ចាស់ទៅដល់ណា សេចក្តីស្រឡាញ់របស់ខ្ញុំចំពោះបងប្អូនឯទៀតៗទៅដល់ណា?



*លោកអភិបាលអូលីវីយេ សម្តែងធម្មទេសនាក្នុងឱកាសបុណ្យចម្លងនៅចំការទៀង។ រូបភាព សុវណ្ណភូមិ*

យប់នេះ ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូន៥៥នាក់ដែលនឹងទទួលជីវិតថ្មីបន្តិចទៀត សម្រាប់បងប្អូនដែលបានយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗនៅក្នុងសេចក្តីសុខ នៅក្នុងសុខដុមរមនា នៅក្នុងភាតរភាព។ ខ្ញុំអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឱ្យយប់នេះយើងភ្ញាក់ស្មារតីដើម្បីនឹកឃើញដល់ពិធីជ្រមុជទឹករបស់យើង នឹកឃើញដល់ជំនឿរបស់យើង។ បងប្អូនជាទីស្រឡាញ់នៅក្នុងភូមិភាគភ្នំពេញទាំងមូល ឱ្យយើងភ្ញាក់ស្មារតីដូចស្ត្រីៗឱ្យយើងស្តាប់ ឱ្យយើងមើលឃើញ និងជាពិសេសឱ្យយើងទៅប្រកាសដំណឹងល្អព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយ ព្រះអង្គណែនាំឱ្យពិភពលោករបស់យើងចេញពីភាពងងឹត ដើម្បីបង្កើតសេចក្តីស្រឡាញ់នៅគ្រប់ទីកន្លែងដែលយើងរស់នៅជាគ្រីស្តបរិស័ទជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។

***ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ***
***អាលេលូយ៉ា អាលេលូយ៉ាង!*** *អាម៉ែន!*

# សកម្មភាពនានារបស់ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



លោកអភិបាល និងលោកបូជាចារ្យបម្រើព្រះសហគមន៍ ក្នុងប្រទេសកម្ពុជា។
*រូបភាព សម្បត្តិ*



ក្រុមសម្ពន្ធកាតូលិក ដើម្បីមេត្តាករុណានិងអភិវឌ្ឍ។ *រូបភាព សុវណ្ណា*



ដើរផ្លូវឈើឆ្កាងនៅលើភ្នំបូកគោ។
*រូបភាព សុវណ្ណវភូមិ*



យុវជនពីរូបដែលរិះគិតពីជីវិតក្នុង
ក្រុមសាឡេស៊ាន។ *រូបភាព ដុនបូស្កូ*



លោកអភិបាលសួរសុខទុក្ខគ្រីស្តបរិស័ទ
នៅកំពង់ស្ពឺ ។ *រូបភាព ហំ*



លោកអភិបាលទាំងបីប្រសិទ្ធីពរលើព្រះលោហិតនៅតាំងគោក ។ *រូបភាព សុវណ្ណភូមិ*



សកម្មភាពធ្វើប្រដាប់ជូតជើងពីស្រកីដូង
នៅភូមិសិប្បកម្ម។ *រូបភាព សុវណ្ណភូមិ*



លោកបូជាចារ្យនិងគ្រីស្តបរិស័ទ
ក្រុងតាខ្មៅចុះសួរសុខទុក្ខអ្នកក្រីក្រ។



អភិបូជាថ្ងៃព្រហស្បតិ៍ពិសិដ្ឋនៅព្រះសហគមន៍
ព្រែកប្រស់។ *រូបភាព សុវណ្ណភូមិ*